គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

**Tonle Sap Technology Demonstrations for Productivity Enhancement**

(TSTD - TA 7305-CAM)

# សៀវភៅណែនាំបច្ចេកទេសស្ដីពី
# ការចិញ្ចឹមបំប៉នមាន់ស្រុកសម្រាប់ទីផ្សារ




ខែ សីហា ឆ្នាំ ២០១៣

# តារាងមាតិកា

**អារម្ភកថា**……………………………………………………………………………………………1

**១. សេចក្តីផ្តើម**…………………………………………………………………………………… 2
១.១. តើការចិញ្ចឹមបំប៉នមាន់ស្រុក មានសារៈសំខាន់ដូចម្តេចខ្លះ? ………………………………… 2
១.២. លក្ខណៈល្អប្រសើរនៃការចិញ្ចឹមបំប៉នមាន់ស្រុក (ពីកូន មានគុណភាព)………………………………2

**២. ការជ្រើសរើសកូនមាន់មកចិញ្ចឹមបំប៉ន** ……………………………………………………4
២.១. តើត្រូវជ្រើសរើសកូនមាន់របៀបណា ដើម្បីចិញ្ចឹមបំប៉នបានធំធាត់ល្អ?…………………………… 4

**៣. ទ្រុងសម្រាប់ចិញ្ចឹមបំប៉នកូនមាន់**……………………………………………………………6
៣.១. តើត្រូវធ្វើទ្រុងមាន់យ៉ាងដូចម្តេច ដើម្បីចិញ្ចឹមបានលទ្ធផលល្អ?…………………………………6
៣.២. តើត្រូវធ្វើទ្រុងកូនមាន់អាយុពី ១ ទៅ ៣០ថ្ងៃ យ៉ាងដូចម្តេច ដើម្បីឱ្យលូតលាស់ល្អ?…………………6
៣.៣. ទ្រុងបំប៉នកូនមាន់…………………………………………………………………………7

**៤. ការផ្តល់ចំណី និងទឹកសម្រាប់កូនមាន់**……………………………………………………10
៤.១. សារៈសំខាន់របស់ចំណី………………………………………………………………………10
៤.២. ការផ្សំចំណីសម្រាប់មាន់ជំទង់ និង មាន់ធំ……………………………………………………11
៤.២.១. សមាសធាតុចំណីដែលសំបូរជាតិសាច់ (ប្រូតេអ៊ីន)……………………………………13
៤.២.២. សមាសធាតុចំណីដែលសំបូរថាមពល……………………………………………………14
៤.២.៣. សមាសធាតុចំណីដែលសំបូរជាតិរ៉ែ……………………………………………………14
៤.២.៤. សមាសធាតុចំណីដែលសំបូរវីតាមីន……………………………………………………15
៤.៣. ការទុកដាក់ចំណី………………………………………………………………………………17
៤.៤. តើត្រូវផ្តល់ចំណីសម្រាប់មាន់ជំទង់ ឬ មាន់ធំ របៀបណាទើបល្អ?…………………………………17

**៥. ការចិញ្ចឹមជន្លេនក្រហមសម្រាប់ជាចំណីបំប៉នបន្ថែម**……………………………………………19
៥.១. តើជន្លេនក្រហម មានសារៈប្រយោជន៍អ្វីខ្លះ?……………………………………………………19
៥.២. តើត្រូវចិញ្ចឹមជន្លេនក្រហម យ៉ាងដូចម្តេច ដើម្បីឱ្យលូតលាស់ល្អ?…………………………………19

**៦. ការផ្តល់ទឹក**…………………………………………………………………………………21
៦.១. ស្នូកចំណី និង ស្នូកទឹក…………………………………………………………………………21

**៧. វដ្តផលិតកម្មមាន់ និង ការថែទាំកូនមាន់**………………………………………………………23
៧.១. វដ្តផលិតកម្មមាន់ ……………………………………………………………………………23
៧.២. ការថែទាំកូនមាន់ទើបញាស់…………………………………………………………………23

**៨. ជីវសុវត្ថិភាព និង ការធ្វើអនាម័យ**……26
៨.១. អនាម័យកន្លែងចិញ្ចឹម……26
៨.២. អនាម័យចំណីអាហារ និង ទឹកផឹក……26
៨.៣. ការរៀបចំការចិញ្ចឹម……27
៨.៤. អនាម័យការឆ្លងពីក្រៅ និង ឧបករណ៍ចិញ្ចឹម……27

**៩. ជម្ងឺសំខាន់ៗរបស់មាន់ ការការពារ និង ព្យាបាល**……29
៩.១. ជម្ងឺមាន់ដែលបង្កដោយពពួកបារាសិត……29
៩.១.១. បារាសិតខាងក្រៅ……29
៩.១.២. បារាសិតខាងក្នុង……30
៩.២. ជម្ងឺមាន់ដែលបង្កដោយពពួកបាក់តេរី និង វីរុស……31
៩.២.១. ជម្ងឺញូវកាសស……31
៩.២.២. ជម្ងឺអុត……32
៩.២.៣. ជម្ងឺអាសន្នរោគ……33
៩.២.៤. ជម្ងឺផ្តាសាយបក្សី……34

**១០. លក្ខណៈទូទៅរបស់ថ្នាំបង្ការ (វ៉ាក់សាំង)**……36

**១១. ការកត់ត្រាចំណាយចំណូលផលិតកម្ម**……38
១១.១. ការកត់ត្រាចំណាយចំណូលផលិតកម្ម……38
១១.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម……40

**ឯកសារយោង**……41

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD) ជាគម្រោងជំនួយបច្ចេកទេសដែលផ្តល់សហ-ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្ត ដោយរដ្ឋាភិបាលហ្វាំងឡង់ មូលនិធិដៃគូអ៊ី-អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជា ចូលរួមបដិភាគមិនមែនជាថវិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ...) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ីជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ ជំនួសមុខឲ្យម្ចាស់ជំនួយ ។ គម្រោង បានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្តល់សេវាព័ត៌មានជនបទ ដើម្បីបង្កើនប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូច ក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។

គម្រោងបានអនុវត្ត *កម្មវិធីធ្វើបង្ហាញបច្ចេកទេសចិញ្ចឹមបំប៉នមាន់ស្រុកសម្រាប់ទីផ្សារ* ក្នុងខេត្តគោលដៅទាំងបួនក្នុង ឆ្នាំ ២០១២ និង ២០១៣។ សៀវភៅណែនាំបច្ចេកទេសស្តីពី **ការចិញ្ចឹមបំប៉នមាន់ស្រុក សម្រាប់ទីផ្សារ** នេះ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវចំណេះដឹងជាមូលដ្ឋានដល់កសិករ និងមន្ត្រីផ្សព្វផ្សាយបច្ចេកទេសសម្រាប់ប្រើប្រាស់ និងផ្សព្វផ្សាយបន្ត។

ការអនុវត្តន៍កម្មវិធីធ្វើបង្ហាញបច្ចេកទេសនេះ ទទួលបានជោគជ័យ ដោយមានការគាំទ្រពីបុគ្គលិកគម្រោងអាចទទួលបានជោគជ័យ ដោយសារមានការគាំទ្រជាប់ជាបន្តពីថ្នាក់ដឹកនាំ និងបុគ្គលិកក្រុមទីប្រឹក្សាគម្រោង ពីលោក **ប្រាក់ ថាវអមិដា** ប្រធានសម្របសម្រួលគម្រោង TSTD និង ជាអគ្គលេខាធិការរង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ លោក **លីវ លាងហ៊ី** ប្រធានក្រុមទីប្រឹក្សាគម្រោង មន្ត្រីនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល និង មន្ត្រីមន្ទីរកសិកម្មខេត្តទាំងបួន។

ទោះបីជាឯកសារនេះ រៀបចំផ្អែកលើបទពិសោធន៍ជាក់ស្តែងទទួលបានជោគជ័យរបស់កសិករ ក៏ពិតមែន ក៏នៅមានចំណុចត្រូវកែលម្អ ដែលយើងខ្ញុំសូមស្វាគមន៍។

**រៀបរៀងដោយៈ**

**លោក អ៊ុំ ណារិន្ទ** អ្នកជំនាញផ្នែកបសុសត្វ នៃគម្រោង TSTD

អ៊ីម៉ែលៈ oumnarin@yahoo.com

# ១. សេចក្តីផ្តើម

ការចិញ្ចឹមបំប៉នមាន់ស្រុក ផ្តល់ប្រភពចំណូលបន្ថែមជាប្រចាំដល់គ្រួសារ ដោយចំណាយពេលទំនេរ និងធនធានមួយចំនួនប៉ុណ្ណោះ។ កូនមាន់ស្រុកនៅកន្លែងភ្ញាស់នេះ ទទួលបានការគ្រប់គ្រងតាមបច្ចេកទេសត្រឹមត្រូវ ជួយមិនឲ្យមាន់ឈឺ និងងាប់ដោយសារជម្ងឺកាចសាហាវនានា។ ពូជមាន់ក្នុងស្រុកមានការពេញនិយមពីអ្នកហូបមានតម្រូវការទីផ្សារខ្ពស់ និងងាយស្រួលលក់ (មានតម្លៃថ្លៃ)។ តាមរយៈបច្ចេកទេសចិញ្ចឹមនេះ កូនមាន់ស្រុក ១ក្បាល (អាយុ ២១ ថ្ងៃ) ចិញ្ចឹមក្នុងរយៈពេលតែ ៨៥ថ្ងៃ អាចទទួលបានទម្ងន់ជាមធ្យម ១,២គីឡូក្រាម។ តាមបទពិសោធន៍កន្លងមក កសិករចិញ្ចឹមអាចទទួលបានប្រាក់ចំណេញសុទ្ធ ក្នុង ១គីឡូក្រាមមាន់រស់ ជាមធ្យមពី ៦.០០០ ទៅ ៧.០០០រៀល ។ ប្រាក់ចំណូលសរុប នឹងកើនឡើង បើកសិករចិញ្ចឹមកូនមាន់ស្រុកបំប៉នយកសាច់កាន់តែច្រើន។

## ១.១. តើការចិញ្ចឹមបំប៉នមាន់ស្រុក មានសារៈសំខាន់ដូចម្តេចខ្លះ?

- ដើម្បីផ្តល់ជាជម្រើសអាហាររូបត្ថម្ភ ឬ ផ្តល់សាច់ ធ្វើជាម្ហូបអាហារ ដែលមានគុណភាពល្អ
- ដើម្បីបង្ហាញ និងផ្សព្វផ្សាយ បច្ចេកវិទ្យាចិញ្ចឹមមាន់សមស្រប ដល់កសិករ
- កាត់បន្ថយរយៈពេលនៃការចិញ្ចឹមមាន់ស្រុក ឆាប់បានលក់ (មកត្រឹម ពី ៣ ទៅ ៤ ខែ)
- ការកាត់បន្ថយលើការទិញម្ហូបចំណី
- ពង្រីកការចិញ្ចឹមទៅតាមតំរូវការទីផ្សារ
- បង្កើតមុខរបរ និងប្រាក់ចំណូលគ្រួសារ
- ចិញ្ចឹមតាមបច្ចេកទេសជីវសុវត្ថិភាព អាចកាត់បន្ថយការឆ្លងរាលដាលជម្ងឺមាន់
- ងាយស្រួលក្នុងការគ្រប់គ្រង (ការផ្តល់ចំណី ការបង្កាត់ពូជ ការការពារ និងអនាម័យ)
- ផ្តល់លាមក សម្រាប់ធ្វើជីដាក់ដំណាំ

## ១.២. លក្ខណៈល្អប្រសើរនៃការចិញ្ចឹមបំប៉នមាន់ក្នុងស្រុក(ពីកូន មានគុណភាព)

ជាទូទៅ យើងសង្កេតឃើញពូជមាន់ដែលល្អ និងមានតម្លៃលើទីផ្សារ គឺ មាន់គក មាន់សំពៅ មាន់ប្រជល់ មាន់កណ្តូង មាន់ចៃ មាន់សំឡី មាន់ក្រញាស់ មាន់ខ្មៅ មាន់ស្លួយ មាន់ក្លឹង។ល។

គុណសម្បត្តិនៃការចិញ្ចឹមមាន់បំប៉នសម្រាប់ទីផ្សារ ៖

- កូនមាន់ដែលមានអាយុ ពី២១ ដល់ ៣០ថ្ងៃ និង ត្រូវបានចាក់វ៉ាក់សាំងការពារជម្ងឺ បានត្រឹមត្រូវ
- កូនមាន់មានសុខភាពលល្អ និងលូតលាស់លឿន
- មិនសូវកើតជម្ងឺ ហើយអាចទប់ទល់ជាមួយជម្ងឺកាចសាហាវបានមួយចំនួន ដោយមានការចាក់វ៉ាក់សាំងការពារជម្ងឺកូនមាន់ ពី ២ ទៅ ៣ មុខ រួចជាស្រេច (ជម្ងឺញូវកាសល កំប្បូរ៉ូ និង អុត )
- ធនទ្រាំទៅនឹងអាកាសធាតុ និងការលំបាកគ្រប់បែបយ៉ាង

- ងាយស្រួលថែទាំ និង ការផ្តល់ចំណី
- មិនទាមទារមេបណ្តើរ កូនមាន់អាចរស់ដោយខ្លួនវា
- សាច់មាន់ស្រុក មានរសជាតិឆ្ងាញ់ និងពេញនិយមលើទីផ្សារ
- តម្រូវការទីផ្សារខ្ពស់ និងមានតំលៃល្អ (មាន់សាច់ ដែលមានទម្ងន់ពី ១ ទៅ១,២គីឡូក្រាម)

# ២. ការជ្រើសរើសកូនមាន់មកចិញ្ចឹមបំប៉ន

## ២.១. តើត្រូវជ្រើសរើសកូនមាន់របៀបណា ដើម្បីចិញ្ចឹមបានធំធាត់ល្អ?

ជាទូទៅ កសិករមិនសូវមានឱកាសច្រើនក្នុងការជ្រើសរើសពូជទេ នៅក្នុងប្រព័ន្ធផលិតកម្មកម្ពុជាទំលាប់នោះ ដោយសារមាន់ភាគច្រើនត្រូវបានងាប់ដោយសារការផ្ទុះជម្ងឺ ឬលក់មុនការផ្ទុះឡើងនៃជម្ងឺ។ ផ្ទុយទៅវិញ ការចាក់វ៉ាក់សាំងការពារអាចសង្ឃឹមថា អត្រារស់រានអាចមានរហូតដល់ ៧០-៨០% ដែលធ្វើឲ្យកសិករមានលទ្ធភាពធ្វើការសង្កេតទៅលើលក្ខណៈ និងស្ថានភាពរបស់មាន់ មុននឹងធ្វើការសម្រេចចិត្តជ្រើសរើសមកចិញ្ចឹម។

ករណី២ យ៉ាងដែលកសិករយើងគួរធ្វើការជ្រើសរើសកូនមាន់ មកចិញ្ចឹមបំប៉ន គឺៈ

### ក. ការជ្រើសរើសកូនមាន់ដែលមានស្រាប់

ក្នុងករណីដែលកសិករមានមាន់ច្រើន (មេ និងបា គ្រប់គ្រាន់) និង ជៀសវាការចិញ្ចឹមមាន់តាមបែបប្រពៃណី ដែលទុកឲ្យមេរបស់វាបណ្តើរតាំងពីតូចរហូតដល់ធំ និងមានការថែទាំកូនមាន់ និង ផ្តល់ចំណីដោយមេរបស់វា។ មេមាន់ខ្លះនៅបណ្តើរកូនរហូតដល់កូនមានអាយុ៣ខែ ទើបចាប់ផ្តើមរកឈ្មោល និង ពងសារជាថ្មី។ ដើម្បីឲ្យការចិញ្ចឹមមាន់បានទទួលទន្និផលខ្ពស់ និងមានកូនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមបំប៉ន យើងគួររៀបចំបំបែកកូនមាន់ពីមេតាំងពីពេលដែលកូនមាន់កើតមកភ្លាមៗ ឬ នៅដំណាក់កាលណាមួយ ដែលយើងគិតថាកូនមាន់អាចស៊ាំនឹងអាកាសធាតុខាងក្រៅ ដោយមិនបាច់ពឹងផ្អែកលើមេរបស់វា។ បន្ទាប់ពីបំបែកកូនមាន់ ត្រូវមានទ្រុងសម្រាប់កូនមាន់។ ទ្រុងសម្រាប់កូនមាន់មានសារៈសំខាន់ ដូចជា ធ្វើឲ្យកូនមាន់កក់ក្តៅ ងាយស្រួលផ្តល់ចំណីដែត្រឹមត្រូវដល់កូនមាន់ កាត់បន្ថយអត្រាស្លាប់របស់កូនមាន់ និង អាចកាត់បន្ថយហានិភ័យពីកត្តាចង្រៃ និងកត្តាផ្សេងៗ។ ដើម្បីទប់ទល់ជាមួយជម្ងឺកាចសាហាវបានមួយចំនួន ដោយមានការចាក់វ៉ាក់សាំងកាពារជម្ងឺកូនមាន់ ពី ២ ទៅ ៣ មុខ រួចជាស្រេច (ជម្ងឺញូវកាស កុំប៉ូរ៉ូ និង អុត) ទៅតាមបទដ្ឋានបច្ចេកទេស។

### ខ. ការជ្រើសរើសកូនមាន់ ដោយទិញពីកសិដ្ឋានឆ្លាស់កូនមាន់

ការជ្រើសរើសកូនមាន់ពីកសិដ្ឋានជាជំរើសដ៏ល្អ ជាពិសេស កសិដ្ឋាន ដែលបានបង្កើតឡើងដោយគម្រោង TSTD ក្នុង ខេត្តទាំងបួន។ បើសិនជាក្នុងតំបន់យើងពុំមានកសិដ្ឋានចិញ្ចឹម និងលក់កូនមាន់ទេ យើងអាចរកទិញកូនមាន់ដែលមាននៅក្នុងភូមិ ដែលស្គាល់ពីប្រវត្តិច្បាស់លាស់ ជាពិសេសមេបា មិនជាន់ឈាម ឬ ផ្ទះដែលកំពុងមានជម្ងឺកើតឡើង។




រូបទី១: ការជ្រើរើសកូនមាន់មកចិញ្ចឹម

## ការជ្រើសរើសកូនមាន់ចិញ្ចឹម

- មានរាងល្អ ភ្លៀវភ្លា ជើងលឿង
- ចេញពីមេបាដែលមានសុខភាពល្អ
- កូនមាន់មានបានចាក់វ៉ាក់សាំងកាពារជម្ងឺឆ្លងបានយ៉ាងតិច ២មុខ (ជម្ងឺញូវកាស និង អុតមាន់)
- ចំពោះកូនមាន់ដែលរោមស្អិតជាប់គ្នា ហើយពោះធ្លាក់ ឬរឹង និងមានពណ៌ខៀវ មិនគួរយកមកចិញ្ចឹមទេ។

> **☠សូមប្រយ័ត្ន**
> មិនត្រូវទិញកូនមាន់ដែលដឹកលក់តាមកង់ ឬម៉ូតូ ឬតំបន់ ដែលធ្លាប់មានជម្ងឺកើតឡើងទេ។

# ៣. ទ្រុងសម្រាប់ចិញ្ចឹមបំប៉នកូនមាន់

## ៣.១. តើត្រូវធ្វើទ្រុងមាន់យ៉ាងដូចម្ដេច ដើម្បីចិញ្ចឹមទទួលបានលទ្ធផលល្អ?

ទ្រុងមានសារៈសំខាន់ណាស់សម្រាប់ការពារមាន់ ជាពិសេសសម្រាប់កូនមាន់ ដោយសារវាមិនត្រឹមតែផ្ដល់សន្តិសុខ និងសុវត្ថិភាពអាចដល់មាន់នៅពេលយប់ពី ចោរកម្ម សត្វលក្ខណៈកាចសាហាវ និង អាច ទប់ទល់អាកាសធាតុប្រែប្រួល ប៉ុណ្ណោះទេ ជាពិសេសកូនមាន់តូចៗ ប៉ុន្តែវាបានបង្កើតលក្ខខណ្ឌចាំបាច់មួយចំនួន ដើម្បីធ្វើការងារសំខាន់ៗមួយចំនួន ដូចជា៖

- ងាយស្រួលក្នុងការគ្រប់គ្រង
- ងាយស្រួលក្នុងការចាក់ថ្នាំការពារ និងការតាមដានជម្ងឺ ការពារការឆ្លងរាលដាលនៃជម្ងឺ ដែលឆ្លងរាតត្បាតពីខាងក្រៅ។
- ងាយស្រួលក្នុងការផ្ដល់ចំណី និងការថែទាំ
- ងាយការពារ និងរារាំងពីការបំផ្លាញដោយសត្វផ្សេងៗ
- ងាយការត្រួតពិនិត្យចំនួនមាន់និងស្ថានភាពសុខភាពមាន់
- ងាយផ្ដុំលាមកមាន់នៅមួយកន្លែង ងាយស្រួលប្រមូលធ្វើជី
- ងាយចាប់មាន់ នៅពេលចង់បរិភោគ និងលក់



រូបទី២: ទ្រុងកូនមាន់ជញ្ជាំងធ្វើពីបន្ទះរនាបឬស្សី

ប៉ុន្តែទ្រុងរបៀបនេះ ត្រូវការចំណាយដើមទុនច្រើនក្នុងការសាងសង់ និង ធ្វើរបងព័ទ្ធជុំវិញ សម្រាប់ឲ្យមាន់ដើរខាងក្នុង ។ ហើយម្យ៉ាងទៀត ត្រូវចំណាយចំណីស្ទើរតែទាំងស្រុងសម្រាប់ផ្ដល់ឲ្យមាន់ស៊ី។

## ៣.២. តើត្រូវធ្វើទ្រុងកូនមាន់អាយុពី ១ ទៅ ៣០ថ្ងៃ យ៉ាងដូចម្ដេច ដើម្បីឱ្យលូតលាស់ល្អ?

- ធ្វើទ្រុងផុតពីដីកំពស់កន្លះម៉ែត្រ (0,៥ម៉ែត្រ)
- បាតទ្រុង និងជញ្ជាំងអាចធ្វើពីបន្ទះឬស្សី ឬ សំណាញ់ដែក ឬ សំណាញ់នីឡុង។
- បាតទ្រុងក្រាលអង្កាម ឬ កំទេចអាចម៍រណា (ដើម្បីរក្សាកំដៅ) រហូតដល់កូនមាន់មានអាយុ ៣០ថ្ងៃ ឬ ១ ខែ ទើបលែងដាក់។
- ជញ្ជាំងទ្រុង និងពីលើទ្រុងពទ្ធ័ដោយបាវ ឬ ក្រដាសដើម្បីរក្សាកំដៅ ពិសេសពេលយប់ និង អាកាសធាតុត្រជាក់។

**បញ្ជាក់:** នៅពេលកូនមាន់អាយុបាន ៣០ថ្ងៃ ត្រូវបញ្ជូនទៅដាក់ក្នុងទ្រុងបំប៉ន រហូតដល់ពេលលក់។



រូបទី៣: ទ្រុងកូនមាន់បាំងជុំវិញសម្រាប់រក្សាកំដៅ



រូបទី៤: សំយាបរោងសម្រាប់ដាក់ទ្រុងកូនមាន់

## ៣.៣. ទ្រុងចំប៉ីនកូនមាន់

កូនមាន់មិនអាចត្រូវបានចិញ្ចឹមនៅក្នុងទ្រុងកូនមាន់រហូតបានទេ ដោយសារទ្រុងមានទំហំតូចហើយកូនមាន់មានចំនួនច្រើន។ យើងត្រូវយកកូនមាន់ចេញពីទ្រុងកូន និងដាក់ទ្រុងបំប៉ន ឬ ទ្រុងមាន់សាច់។ យើងមិនត្រូវយកកូនមាន់ទៅដាក់ជាមួយមាន់ធំៗបានទេ ព្រោះវាមិនអាចស៊ីចំណីទាន់មាន់ធំ និងមានការចឹកគ្នា ។ដូច្នេះ យើងត្រូវដាក់ដែលមានអាយុប្រហាក់ប្រហែលគ្នា។

តាមការគាំទ្របច្ចេកទេស និងបទពិសោធន៍ នៃគម្រោងTSTD ការសាងសង់ទ្រុងសម្រាប់ការចិញ្ចឹមបំប៉នមាន់សម្រាប់ទីផ្សារ គឺចាប់បាច់អនុវត្ត ដូចខាងក្រោមៈ

- ទីតាំងសម្រាប់សង់ទ្រុង មានស្ថានភាពមិនលិចទឹកនៅរដូវវស្សា និងមានខ្យល់ចេញចូលបានល្អ
- ជញ្ជាំងរោងដេកយប់ ព័ទ្ធដោយរនាបឫស្សី
- ទំហំទ្រុង (តួទ្រុង) គឺមានទទឹង ៣ម៉ែត្រ  បណ្តោយ ៦ម៉ែត្រ ដែលខ័ណ្ឌជា៣បន្ទប់ ដាច់ៗពីគ្នា និងទីធ្លាចេញមកខាងក្រៅ ដែលខ័ណ្ឌជា ៣ បន្ទប់ មានចម្ងាយពី ២,៥ម៉ែត្រ ឬ ៣ម៉ែត្រ ដោយហ៊ុំព័ទ្ធដោយសំណាញ់ តាមបន្ទាប់និមួយៗ សម្រាប់មាន់ដើរខាងក្រៅ  ហាលថ្ងៃ និងកន្លែងដាក់ចំណីនិងទឹក។ ក្នុងបន្ទប់និមួយៗ អាចដាក់មាន់ចំនួន ៥0ក្បាល។
- នៅខាងក្នុងមានផ្ទើរសម្រាប់មាន់ដេក ដែលមានកំពស់ពីដី 0,៧ម៉ែត្រ និង ទទឹងប្រវែង 0,៧ម៉ែត្រ
- ត្រូវធ្វើជណ្តើរសម្រាប់ មាន់ឡើងដេក
- ក្នុងផ្ទៃដីមួយម៉ែត្រការ៉េ (កន្លែងដេកយប់) អាចដាក់មាន់បាន ៧ ទៅ ៨ ក្បាល
- ជញ្ជាំងទ្រុងធ្វើពីបន្ទះឬស្សី ដែលគម្លាតពីមួយទៅមួយប្រវែង ១សង់ទីម៉ែត្រ
- ទ្រុងត្រូវមានកំពស់ជើងរៀង ១,៧ម៉ែត្រ និងសរសរកន្លោងកំពស់ ៣,២ម៉ែត្រ
- ដំបូលគួរធ្វើពីស្បូវ ឬ ពីស្លឹកត្នោត
- គ្រោងទ្វារធ្វើពីកូនឈើ ឬ ពីឫស្សី
- បាចកំបោរក្នុងទ្រុង រាល់មុនដាក់មាន់ចិញ្ចឹម ១ អាទិត្យ

- ក្រាលអង្កាមក្នុងទ្រុងកម្រាស ១ ទៅ ២សង់ទីម៉ែត្រ
- ការការពារវិញទ្រុង ជាការល្អត្រូវដាំដើមកន្ទំថេត ដើមងប់ ត្រកួន ដំឡូងឈើ ដើម្បីផ្តល់ជាអាហារបន្ថែមដ៏ល្អសម្រាប់មាន់។



រូបទី៥: ការពាចកំបោរខាងក្នុងទ្រុង



រូបទី៦: ផ្ទើរមាន់ដេកធ្វើពីបន្ទះឫស្សី និងក្រាលអង្កាម

យើងអាចចិញ្ចឹមកូនមាន់ពីអាយុ ២១ថ្ងៃ ក្នុងរយៈពេលពី ៣ ខែ ៣ខែ កន្លះ នឹងអាចលក់បាន ហើយមាន់អាចមានទម្ងន់ពី ១,២គីឡូក្រាម ទៅ១,៥គីឡូក្រាម។ តម្លៃមាន់ជាមធ្យម ថ្លៃ ពី ១២.០០០ ទៅ ១៦.០០០រៀល ក្នុង១គីឡូក្រាម។




រូបទី៧: ទ្រុងបំប៉នកូនមាន់ ដោយខ័ណ្ឌជា៣ខ័ណ្ឌ ឬ ប្រឡោះ

**គួរចងចាំ៖**

- កសិករអាចប្រើប្រាស់ធនធានដែលអាចរកបានតាមមូលដ្ឋាន ដូចជា ធាងដូង ធាងត្នោត កូនឬស្សីកូនឈើ សំណាញ់ ស្បៃនីឡុង ឬ មងចាស់ៗ.......សម្រាប់សាងសង់ទ្រុងមាន់។
- កសិករអាចដាំរុក្ខជាតិមួយចំនួន ដូចជា ក្រកូន ផ្ទី ជាចំណីបរិភោគផង និងជាចំណីមាន់ផង។
- ជុំវិញរបងទ្រុងមាន់ គួរដាំដើម ដំឡូងឈើ កូនកន្ទំថេត និងល្ពៅខ្ទង សម្រាប់ចំណីមាន់....។ល។
- បើមានការចិញ្ចឹមដង្កូវ ជាការប្រសើរបំផុត សម្រាប់ចំណីមាន់




រូបទី៨: តួរោងទាំងមូលរបស់ទ្រុងកូនមាន់បំប៉ន

# ៤. ការផ្តល់ចំណី និងទឹក សម្រាប់កូនមាន់

ជាទម្លាប់របស់កសិករយើងភាគច្រើន ការផ្តល់ចំណីមាន់ពុំបានយកចិត្តទុកផ្តល់ឲ្យមាន់តាមតម្រូវការនៃការលូតលាស់របស់មាន់ទេ គឺពួកគាត់តែងតែប្រលែងមាន់ឲ្យរកស៊ីខ្លួនឯងពាសវាលពាសកាល ។

ការចិញ្ចឹមមាន់ ដាក់ទ្រុងបង្ខាំង មានន័យថាកូនមាន់ពឹងផ្អែកទាំងស្រុងទៅលើការផ្តល់ចំណីនិងថែទាំដល់ពួកវា។ ដូច្នេះ តម្រូវការចំណីនេះ មានការកើនឡើង ទៅតាមអាយុ និង ទម្ងន់របស់វា។ មាន់ត្រូវការចំណីដែលមានគុណភាពសម្រាប់ទ្រទ្រង់រាងកាយ ការរីកលូតលាស់ ផលិតកម្មស៊ុត និង សាច់។ កូនមាន់តូចៗ ដែលមានអាយុពី ១ ថ្ងៃ ដល់ ៤៥ថ្ងៃ ត្រូវការចំណីដែលមានគុណភាពល្អ និង មានគុណភាពខ្ពស់ដើម្បីការលូតលាស់របស់វា។

## ៤.១. សារៈសំខាន់របស់ចំណី

ចំណីជាប្រភពដ៏សំខាន់ សម្រាប់ផ្តល់នូវថាមពល ជាតិសាច់ សារធាតុរ៉ែ និងវីតាមីនដែលធានាឲ្យមាន់ មាន៖

- សុខភាពល្អ
- ការលូតលាស់ធំធាត់លឿន
- ការបន្តពូជល្អ

**ដូច្នេះ ក្នុងចំណីមាន់ ត្រូវមានសមាសធាតុអ្វីខ្លះ?**

មាន់ត្រូវផ្តល់នូវអាហារមានគុណភាព និង បរិមាណគ្រប់គ្រាន់ដូចជា ជាតិសាច់ ថាមពល វីតាមីន និង សារធាតុរ៉ែ ។ ក្រៅពីចំណី គេត្រូវផ្តល់ទឹកឲ្យមាន់ ឱ្យបានគ្រប់គ្រាន់ជាប្រចាំ។

កូនមាន់ដែលមានអាយុក្រោម ៣អាទិត្យ ត្រូវការចំណីដែលមានសាធាតុចិញ្ចឹមខ្ពស់ ជាពិសេសប្រូតេអ៊ីន (ពី ២០ ទៅ ២២%)។ ការផ្តល់តែចំណីក្នុងស្រុកតែមួយមុខ មិនមានសាធាតុចិញ្ចឹមគ្រប់គ្រាន់ សម្រាប់កូនមាន់នោះទេ។ វាធ្វើឲ្យកូនមាន់លូតលាស់យឺតជាង កូនមាន់ដែលស៊ីចំណីក្នុងស្រុកលាយចំណីទិញពីផ្សារ (រោងចក្រសុទ្ធ) ។ បើយើងមានលទ្ធភាពគួរឲ្យកូនមាន់ស៊ីចំណីរោងចក្រសុទ្ធ ព្រោះក្នុងកំឡុងពេលនេះកូនមាន់ត្រូវការចំណីតិច យើងក៏មិនសូវចំណាយប្រាក់ច្រើនដែរ។ ជាធម្មតាកូនមាន់ចំនួន១០ក្បាល ដែលផ្តល់ចំណីរោងចក្រសុទ្ធក្នុងរយៈពេល ២១ ថ្ងៃដំបូងស៊ីអស់ ២គីឡូក្រាមតែប៉ុណ្ណោះ។

ក្នុងករណីយើងមិនមានលទ្ធភាព យើងអាចកាត់បន្ថយការចំណាយការទិញចំណីពីផ្សារ ដោយលាយ

ដោយលាយចំណីក្នុងស្រុកពាក់កណ្តាល (ឧទាហរណ៍ៈ កំទេចពោត ៥ភាគ ចុងអង្ករ ៣ភាគ និង កន្ទក់ ២ភាគ) ជាមួយនឹងចំណីរោងចក្រពាក់កណ្តាល គឺ ១០ភាគ)។ ដើម្បីបង្គ្រប់សារជាតិសាច់ យើងអាចផ្តល់បន្ថែមនូវចំនួនកូនត្រី និងកូនសត្វល្អិតៗ ដូចជាកណ្តៀរ ជន្លេនជាដើម។

ចំពោះកូនមាន់អាយុក្រោម ១ខែ ត្រូវផ្តល់ចំណីបាវគ្រាប់ល្អិត (ផ្សំស្រេច) ឲ្យបានច្រើនដង (ពី៤ ទៅ ៥ដង) ក្នុងមួយថ្ងៃ ។ ពេលអាយុជិត ១ខែ ត្រូវលាយបន្ថែមជាមួយចុងអង្ករ និង កន្ទក់ម៉ត់ លេខ១។

ក្នុងរយៈកាលអាយុក្រោម ៣អាទិត្យ ត្រូវផ្តល់ចំណីផ្សំស្រេចសម្រាប់កូនមាន់ ហើយបន្ទាប់ពីនេះ ត្រូវលាយចំណី ដូចជា ចុងអង្ករ ពោត... ដែលកិនឱ្យល្អិតៗ ដើម្បីឱ្យកូនមាន់ងាយស្រួលលេបចូល ។ ជាដំបូង ត្រូវលាយជាមួយចំណីផ្សំ ដែលមានក្នុងភូមិប្រហែល ២០% និង នៅអាទិត្យបន្ទាប់ ប្រហែល ៣០%។




*ការផ្សំចំណីសម្រាប់កូនមាន់អាយុក្រោម ៣ សប្តាហ៍*

## ៤.២. ការផ្សំចំណី សម្រាប់មាន់ជំទង់ និងមាន់ធំ

មាន់ជំទង់ និងមាន់ធំ ត្រូវការចំណីច្រើនជាងកូនមាន់។ មាន់ជំទង់ និងមាន់ធំ ត្រូវការ ប្រូតេអ៊ីន ចន្លោះពី ១៦ ទៅ ១៨%។ គេអាចប្រើប្រាស់ចំណី ដែលអាចរកបាននៅក្នុងមូលដ្ឋាន ចំណីទិញពីផ្សារ (បើសិន មានលទ្ធភាព) រួមផ្សំនឹងការបន្ថែមនូវម្សៅប្រេមិច វីតាមិន ឬ សំបកខ្យងខ្ចៅ ព្រមទាំងការបង្កើតកន្លែងឲ្យមាន់អាចរុករកសត្វល្អិត សម្រាប់បន្ថែមជាតិសាច់។

គេអាចលាយចំណីសម្រាប់មាន់ជំទង់ និងមាន់ធំ ដោយប្រើចំណីផ្តល់ ថាមពលដែលមានប្រភពពីគ្រាប់ធញ្ញជាតិ ដូចជា កន្ទក់ ស្រូវត្រាំ កំទេចពោត និងបន្ថែមចំណីបៃតងបន្ថែម ដែលជាប្រភពផ្តល់ប្រូតេអ៊ីន ដូចជា ស្លឹក

កន្ធំថេត ត្រកួនហាន់ឲ្យល្អិត ចកបាយទា ស្លឹកដំឡូងមីហាលឲ្យស្ងួត.....បរិមាណទាំងពីរប្រភេទនេះ ត្រូវលាយក្នុងចំនួនស្មើគ្នា។ បន្ទាប់ពីការលាយចំណីពីរបញ្ចូលគ្នាហើយ យើងអាចដាក់ឲ្យមាន់ស៊ីបាន។ បើអាចរកបាន យើងត្រូវបន្ថែមកូនត្រីល្អិតៗ ឬ ចំណីផាងចក្រ សំបកខ្យង និងម៉្សៅប្រេមិចបន្ថែមទៅក្នុងចំណីដែលបានលាយរួចហើយនេះ។

យើងអាចផ្សំចំណីមាន់ធំឲ្យបានត្រឹមត្រូវដោយ អនុវត្តតាមវិធី៖ លាយកំទេចពោត ៤ភាគ កន្ទក់ ៣ភាគ និងស្រូវត្រាំឲ្យចេញពន្លក ឬ ចុងអង្ករ ៣ភាគ លាយជាមួយចំណីមានប្រភពបន្លែ ១០ភាគ ចំណីផាងចក្រ ឬ កូនត្រីល្អិតៗ ២ភាគ ម្សៅប្រេមិច (តាមការណែនាំប្រើប្រាស់របស់ក្រុមហ៊ុន) និងសំបកខ្យងខ្លៅបន្តិចបន្តួច។




រូបទី៩: ចំណីលាយរួចសម្រាប់មាន់ជំទង់ ឬ មាន់ធំ

## គួរយល់ដឹង៖

**☞ ការបន្ថែម ម្សៅប្រេមិច ក្នុងចំណី៖**

ជួយបន្ថែមសារជាតុរ៉ែ និង វីតាមីនមួយចំនួន ដែលមិនអាចមានគ្រប់គ្រាន់នៅក្នុងចំណីដែលធ្វើឲ្យមាន់ធាប់ធំ និងមានសភាពធាត់ ដែលជាការចាប់អារម្មណ៍សម្រាប់ឈ្មួញ និង អ្នកហូប។ ផ្ដល់ប្រេមិចឲ្យមាន់ស៊ី ដោយលាយជាមួយចំណី (ចំណីក្នុងស្រុក) ជាពិសេស ១ ខែមុនពេលលក់ ។

**☞ កំទេចពោត និង ស្លឹកដំឡូងមីស្ងួត៖**

ការផ្ដល់កំទេចពោត និងស្លឹកដំឡូងមីស្ងួត អាចជួយដល់ការធំធាត់របស់មាន់។ វាមានសារជាតុសង់តូហ្វីល ដែលអាចធ្វើឲ្យមាន់ កាន់តែមានស្បែកលឿង ដែលជាតម្រូវទីផ្សារក្នុងស្រុក។ ផ្ដល់កំទេចពោតឲ្យមាន់ស៊ី រហូតដល់ ចំនួន ៥០ក្រាម (កន្លះខាំ) សម្រាប់មាន់១០ក្បាល។

### ៤.២.១. សមាសធាតុចំណី ដែលសំបូរជាតិសាច់ (ប្រូតេអ៊ីន)

ប្រូតេអ៊ីនមានសារៈសំខាន់សម្រាប់ជួយការលូតលាស់របស់រាង្គកាយ សាច់ ស្បែក សម្រាប់ផលិតពង ។ ប្រូតេអ៊ីន អាចរកបានពី កន្ទក់ ចុងអង្ករ ត្រី ម្សៅត្រី ម្សៅត្រីក្រៀម កង្កែប ជន្លេន សត្វល្អិត ពពួកសណ្ដែក សាច់ដូងស្ងួត ស្លឹកកន្ទុំថេត ស្លឹកដំឡូងឈើស្ងួត ត្រកួន ចកបាយទា.....។ល។

ចំពោះប្រភេទរុក្ខជាតិបន្លែត្រូវហាលឲ្យស្ងួតល្អ និង បុកឱ្យម៉ត់មុនឱ្យមាន់ស៊ី។ ចំណែកឯ ការកែច្នៃស្លឹកដំឡូងឈើស្ងួតជាប្រភពប្រូតេអ៊ីន អាចអនុវត្តដូចតទៅ៖

- យកតែស្លឹកដំឡូងមីផ្នែកខាងចុងប្រហែល ៣ ទៅ ៤ តឹក
- កាប់ចិញ្ច្រាំស្លឹកដំឡូងមីឲ្យតូចល្អិត ហើយហាលឱ្យស្ងួតល្អ
- បន្ទាប់មកយកស្លឹកដែលស្ងួតបុកឲ្យម៉ត់ជាម្សៅ
- លាយម្សៅស្លឹកដំឡូងមីស្ងួត ជាមួយសារធាតុផ្សំចំណីផ្សេងៗទៀត ដែលកសិករមាន។




រូបទី១០: ប្រភពចំណីដែលផ្ដល់ប្រូតេអ៊ីន

### ៤.២.២. សមាសធាតុចំណីដែលសំបូរថាមពល

ជាសារធាតុមួយជួយផ្តល់ថាមពលក្នុងការរស់នៅ ផលិត ឬ ស៊ីចំណី និង ការធ្វើចលនា ។ ប្រភពថាមពលអាចមាននៅក្នុង ពោត ចុងអង្ករ កន្ទក់ កាកដូងស្ងួត មើមរុក្ខជាតិ កាកសំណល់បន្លែ ដំឡូងជ្វា កាកសំណល់ផ្លែឈើ ពពុះស្កត្នោត ស្ករ កាកសំណល់ប្រេង-ខ្លាញ់....។




រូបទី១១: ប្រភពចំណីអាហារដែលផ្តល់ថាមពល

ចំពោះមើមដំឡូងមី និងត្រាវ គេអាចកាត់ហាលថ្ងៃ បន្ទាប់មកបុក ឬ កិនឲ្យម៉ត់សម្រាប់ចំណីមាន់។

✌ ចូរប្រយត្ន័! ចិតយកសំបកមើមដំឡូងចេញ ពីព្រោះវាមានជាតិពុល

### ៤.២.៣. សមាសធាតុចំណី ដែលសំបូរជីវជាតិរ៉ែ

សារធាតុរ៉ែ ពិសេសជាតិ កាល់ស្យូម មានសារៈសំខាន់ធ្វើឲ្យឆ្អឹងលូតលាស់ល្អ និងបង្កើតសំបកស៊ុត។ ចំពោះមាន់ដែលចិញ្ចឹមព្រលែង មិនមានបញ្ហាកង្វះសារធាតុរ៉ែទេ ព្រោះវាអាចរកបានដោយខ្លួនវានៅក្នុង ធម្មជាតិ។ កង្វះជាតិកាល់ស្យូម និងផូស្វ័រ បណ្តាលឱ្យមាន់លូតលាស់យឺត មេមាន់រាគពង (ពងចេញមក មានសំបក ទន់) និង ចឹកស៊ីពង ឬ សំបកពងខ្លួនឯង។ ប្រភពនៃជីវជាតិរ៉ែមានៈ សំបកខ្យងខ្ចៅ ឆ្អឹង ត្រី អំបិល ថ្លើមសត្វ។




រូបទី១២: ការផលិតម្សៅកាល់ស្យូម

### ៣.២.៤. សមាសធាតុចំណី ដែលសំបូរវីតាមីន

ចំណីដែលសំបូរទៅដោយវីតាមីនមានៈរុក្ខជាតិបៃតង ស្មៅ ផាងស្លែ ត្រកួន ចក ។ល។ ចំពោះមាន់ ដែលលែងឲ្យដើររកស៊ីខ្លួនឯង ពុំសូវមានបញ្ហាចំពោះការកង្វះវីតាមីនទេ ព្រោះវាអាចស៊ីស្មៅ និង ប្រភេទរុក្ខជាតិពណ៌បៃតងបានគ្រប់គ្រាន់។




រូបទី១៣: ទ្រុងកូនមាន់បាំងជុំវិញសម្រាប់រក្សាកំដៅ




រូបទី១៤: រុក្ខជាតិដែលសំបូរវីតាមីន

**តើត្រូវរៀបចំថ្នាលស្មៅ និង បន្លែជាចំណីមាន់ យ៉ាងដូចម្តេច?**

កសិករគួរតែធ្វើថ្នាលដាំស្មៅច្រើនប្រភេទ លាយជាមួយត្រកួននៅជិតផ្ទះ ឬ ជិតទ្រុងមាន់ ដើម្បីងាយស្រួលផ្គត់ផ្គង់ចំណីមាន់ ដែលជួយកាត់បន្ថយការចំណាយលុយទិញ ឬ ចំណាយពេលវេលាច្រើនសម្រាប់ដើររក។មុនផ្តល់ឲ្យមាន់ស៊ី ត្រូវហាន់វាឱ្យល្អិតៗជាមុនរួចយកទៅច្របល់លាយជាមួយចំណីផ្សេងៗទៀត។



រូបទី១៥: ថ្នាលដាំស្មៅលាយជាមួយត្រកួន



រូបទី១៦: ហាន់ស្មៅ និងត្រកួន ឲ្យល្អិតៗ

## ៣.៣. ការទុកដាក់ចំណី

ចំណីដែលបានផ្សំហើយងាយរលួយ ដោយសារមានការបំផ្លាញដោយសារសត្វកណ្តុរ និងសត្វល្អិតផ្សេងៗ ...។ល។ ដូច្នេះ ដើម្បីរក្សាគុណភាពចំណីបានល្អ និង ជៀសវាងការខាតបង់ចំណី យើងត្រូវអនុវត្ត ដូចខាងក្រោម៖

- ចំណីទុកក្នុងថង់ ការ៉ុង ឬបាវ ដែលចងមាន់ជិត
- រក្សារទុកក្នុងពាង ឡាំងឈើ ឬទីកន្លែងមួយ ដែលបិទជិត មិនឲ្យសត្វចូលបាន
- រក្សាទុកឲ្យផុតពីទីកន្លែងសើម ឬចំទឹកភ្លៀង ឬគ្របប្លាស្ទិចឲ្យជិត ជៀសវាងភ្លៀងសាច់

☞ **ចំណាំ៖**

- លាយចំណីសម្រាប់រយៈពេលតែ៤ សប្តាហ៍ប៉ុណ្ណោះ
- វត្ថុដើមប្រើក្នុងការលាយចណី ត្រូវឲ្យស្ងួត
- ក្នុងករណីលាយជាមួយចកបាយទា ឬ ត្រួន ត្រូវលាយភ្លាយ ហើយឲ្យមាន់ស៊ីភ្លាម

## ៣.៤. តើត្រូវផ្តល់ចំណីសម្រាប់មាន់ជំទង់ ឬ មាន់ធំ ដោយរបៀបណា ទើបល្អ?

ត្រូវផ្តល់ចំណីឱ្យមាន់បាន ពី២ ទៅ ៣ដង ក្នុងមួយថ្ងៃ ដោយលាយបញ្ចូលគ្នារវាងចំណីបាវ (ផ្សំស្រេច) ៥0% និង ចំណីដែលមានក្នុងភូមិ ៥0% (ដូចជា ជាមួយកន្ទក់ ចុងអង្ករ និងស្រូវ ជាដើម)។ បន្ថែមលើនេះ ត្រូវហាន់ ឬ ចិញ្ច្រាំត្រកួន ចំណីបន្លែបៃតងផ្សេងៗទៀត សម្រាប់លាយជាមួយចំណីគ្រាប់ ឲ្យមាន់ស៊ីបន្ថែម ទៀត។




<u>រូបទី១៧</u>: ការលាយចំណីជាមួយបន្លែ (ចក ស្មៅត្រកួន...) និង ការផ្តល់ឲ្យមាន់ស៊ី

# ៥. ការចិញ្ចឹមជន្លេនក្រហម សម្រាប់ជាចំណីបំប៉នបន្ថែម

ឆ្ន✵ឆ្ន

## ៥.១. តើជន្លេនក្រហម មានសារៈប្រយោជន៍អ្វីខ្លះ?

- ងាយស្រួលចិញ្ចឹម
- ជន្លេនសំបូរដោយប្រូតេអ៊ីន
- ផ្តល់ជាចំណីជាតិសាច់ (ប្រូតេអ៊ីន) សម្រាប់ឲ្យមាន់លូតលាស់ល្អ
- ជួយកាត់បន្ថយការចំណាយលើចំណីសម្រាប់ចិញ្ចឹមមាន់



រូបទី១៨: ពូជជន្លេនក្រហម

## ៥.២. តើត្រូវចិញ្ចឹមជន្លេនយ៉ាងដូចម្តេច ដើម្បីឲ្យលូតលាស់ល្អ?

ក- ទីកន្លែងសមស្របសម្រាប់ចិញ្ចឹមជន្លេន

- មានទីទួលមិនលិចទឹក ឬទឹកហូរកាត់
- មានផ្ទៃដីបាតរាបស្មើ
- មិនមានសំបុកស្រមោច នៅក្បែរ
- ធានាសុវត្ថិភាពពីការបំផ្លាញពីកត្តាផ្សេងៗ

ខ- របៀបរៀបចំការចិញ្ចឹម

ដើម្បីឲ្យបានជោគជ័យ ត្រូវអនុវត្តជាបន្តបន្ទាប់ដូចខាងក្រោម:

- ដាក់របាព័ទ្ធជុំវិញ ២ ជាន់ផុតពីដី ដែលមានទទឹង១,២ម៉ែត្រ បណ្តោយ ២,៥ ម៉ែត្រ ទៅ ៣ ម៉ែត្រ និង កំពស់ 0,៣ម៉ែត្រ (៣តឹក)។
- របាខាងក្រោមមានកំពស់ពីដី 0,១៥ ម៉ែត្រ និងរបាខាងលើមានកំពស់ពីដី 0,៣ ម៉ែត្រ
- ជញ្ជាំង និងបាតក្រាលដោយផ្ទាំងកៅស៊ូក្រាស់ រួចចោះរន្ធតូចៗនៅបាត
- ដាក់លាមកគោស្រស់កំរាស់ 0,១ម៉ែត្រ (១តឹក)

- ស្រោចទឹកឱ្យសើម ទើបដាក់ពូជជន្លេន បន្ទាប់មកអាចស្រោចទឹកពីលើបន្តិចទៀត
- ធ្វើដំបូលការពារកំដៅ និងភ្លៀងឲ្យបានជិតល្អ
- ធ្វើគម្របពីលើដើម្បីការពារពីការស៊ីបំផ្លាញពីសត្វផ្សេងៗ (សត្វគីង្គក់ ហ៊ីង កង្កែប ថ្លែន ស្រមោច...)



រូបទី១៩: កាធ្វើដំបូលការពារកំដៅ/ភ្លៀង និង ការដាក់ពូជជន្លេនក្រហមចិញ្ចឹម

គ- របៀបថែទាំ និងផ្តល់ចំណីជន្លេន

- ស្រោចទឹករៀងរាល់ ២ថ្ងៃម្តង ការពារកុំឲ្យស្ងួត
- បន្ថែមចំណីដោយលាមកគោ ៣ ថ្ងៃ ម្តង

ឃ- ការផ្តល់ចំណី(ជន្លេនក្រហម) ឲ្យមាន់ស៊ី

- រយៈពេល ២ ខែអាចប្រមូលផលជន្លេនឲ្យមាន់ស៊ីបាន
- អាចផ្តល់ឲ្យមាន់ស៊ី ពី៣ ទៅ ៤ជន្លេន ក្នុងមាន់១ក្បាលក្នុង ១ថ្ងៃ។



រូបទី២០: ការដាក់ជន្លេនឲ្យមាន់ ជាចំណីបន្ថែម

# ៦. ការផ្តល់ទឹក

ទឹកមានសារៈសំខាន់ណាស់នៅក្នុងការចិញ្ចឹមមាន់យើងចាំបាច់ផ្តល់ទឹកឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់មាន់ ជាពិសេសនៅរដូវក្តៅ (រដូវក្តៅ ពិសេសខែ មីនា និង មេសា ) ។

មាន់ត្រូវការទឹកផឹកគ្រប់ពេលវេលា ដើម្បីការលូតលាស់ និង មាន់អាចស្លាប់ ប្រសិនបើ គ្មានទឹកផឹករយៈពេល ២៤ ម៉ោង។ ត្រូវផ្តល់ទឹកស្អាតជានិច្ច និង គ្រប់ពេល។

- មេមាន់ ១០ ក្បាល ត្រូវការទឹក ៤ លីត្រ ឬ ច្រើនជាងនេះ ក្នុងមួយថ្ងៃ
- កូនមាន់ ១០ ក្បាល ត្រូវការទឹក ១ កែវ ក្នុងមួយថ្ងៃ

**ការប៉ាន់ប្រមាណទៅលើការស៊ីចំណី និងផឹកទឹក នៃមាន់ពូជក្នុងស្រុកចិញ្ចឹមដាក់ទ្រុង**

| អាយុ មាន់ (សប្តាហ៍) | ការស៊ីចំណី (គីឡូក្រាម សម្រាប់មាន់ ១០ក្បាល ក្នុងមួយថ្ងៃ ) | ការផឹកទឹក (លីត្រ សម្រាប់មាន់ ១០ក្បាល ក្នុងមួយថ្ងៃ |
|---|---|---|
| ១ - ៥ | ០,១៥ - ០,៣ | ០,២- ១ |
| ៦ - ១០ | ០,៤ - ០,៦ | ១,១ - ១,៩ |
| ១១ - ១៦ | ០,៧ - ០,៧៥ | ២,៣ - ២,៥ |
| ១៧ - ២១ | ០,៨ | ២,៧ |
| ២២ - ២៤ | ០,៨ - ១ | ២,៨ - ៣ |

## ៦.១. ស្នូកចំណី និងស្នូកទឹក

ត្រូវដាក់ស្នូកទឹក និងស្នូកចំណីឲ្យបានគ្រប់គ្រាន់សម្រាប់មាន់ ។ បច្ចុប្បន្ន ស្នូកទឹកងាយស្រួលទិញ នៅតាមទីផ្សារ តាមខេត្តក្នុងប្រទេសកម្ពុជា ដូចជា ស្នូកទឹកធ្វើពីប្លាស្ទិច ដែលអាចប្រើសម្រាប់ការចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម។ សម្រាប់គ្រួសារកសិករ ដែលចិញ្ចឹមមាន់ប្រមាណ ៥០ក្បាល ក្នុងសារៗ កសិករអាចទិញស្នូកទឹកពីផ្សារ ចំនួនពី ៣ ទៅ ៤ គ្រឿង គឺអាចគ្រប់គ្រាន់ ហើយអាចប្រើប្រាស់ បានរយៈពេលពី ២ ទៅ ៣ ឆ្នាំ ប្រសិនបើថែទាំ ទុកដាក់បានល្អ។



រូបទី២១: ស្នូកទឹកប្លាស្ទិច

ដើម្បីកាត់បន្ថយការចំណាយទិញ និងការកំពប់បាត់បង់ចំណី កសិករគួរកែច្នៃនូវសំភារៈដែលមានស្រាប់នៅក្នុងភូមិ ឬ មានតម្លៃថោកៗ សម្រាប់ធ្វើជា ស្នូកចំណី ។ អ្នកចិញ្ចឹមអាចយកឫស្សី ប៊ីដុងជ័រ ឬ កានជ័រ មកច្នៃជា ស្នូកចំណី ដែលបង្ហាញដូចរូបខាងក្រោម។



<u>រូបទី២២.ក</u>: ស្នូកចំណីកូនមាន់ ធ្វើពីឫស្សី



<u>រូបទី២២.ខ</u>: ស្នូកចំណីមាន់ធំ និង មាន់ជំទង់ ធ្វើពីធុងជ័រ និង ប៊ីដុងជ័រ

# ៧. វដ្តផលិតកម្មមាន់ និងការថែរក្សាកូនមាន់

ៜ✵ៜ

## ៧.១. វដ្តផលិតកម្មមាន់

ដើម្បីចិញ្ចឹមមាន់បានរីកចំរើន កសិករគួរស្វែងយល់ពីវដ្តផលិតកម្មមាន់ ដូចបង្ហាញក្នុងរូបខាងក្រោម៖

វដ្តផលិតកម្ម ឬ រយៈពេលញាស់មួយសំបុករបស់មេមាន់ ១ក្បាល មានរយៈពេល ៥៦ថ្ងៃ ប្រសិនបើអ្នកចិញ្ចឹមអនុវត្តតាមបច្ចេកទេសបង្ហាញខាងក្រោម ។ ដូច្នេះ មេមាន់ ១ក្បាល អាចទទួលបានកូនមាន់ជាមធ្យម ពី ៥ ទៅ ៦ សំបុក ក្នុង ១ឆ្នាំ។




រូបទី២៣: គំនូសតាងវដ្តផលិតកម្មមាន់

សំគាល់: បើសិនជាកសិករមានបទពិសោធន៍គ្រប់គ្រាន់ នោះកសិករអាចបំបែកកូនចេញពីមេ បន្ទាប់ពីញាស់រួចភ្លាម ដូចច្នេះក្នុង ១ឆ្នាំ កសិករអាចទទួលបានកូនមាន់ពី ៧ ទៅ ៨សំបុក សម្រាប់មេមាន់១ក្បាល។ ប៉ុន្តែកូនមាន់ទាំងនោះ ត្រូវការថែរក្សាយ៉ាងត្រឹមត្រូវ។

## ៧.២. ការថែរក្សាកូនមាន់ទើបញាស់

កូនមាន់ដែលទើបញាស់ងាយរងគ្រោះ និង អត្រាងាប់ខ្ពស់ប្រសិនបើមិនបានថែរក្សាត្រឹមត្រូវ ។ ដូច្នេះដើម្បីការពារកូនមាន់កុំឲ្យងាប់ ត្រូវអនុវត្ត ដូចខាងក្រោម៖

- ថែរក្សានៅកន្លែងដែលមានសុវត្ថិភាព
- កន្លែងដែលមានបរិយាកាសក្តៅល្មម និងស្អាតល្អ
- ផ្តល់នូវទឹក និងចំណីអាហារដែលងាយស្រួលរំលាយ និងគ្រាប់ល្អិតៗ គ្រប់គ្រាន់។

*តើយើងត្រូវថែរក្សាកូនមាន់ ដែលទើបនឹងញាស់ និងបំបែកមេ ដោយរបៀបណា?*

❖ <u>ការចិញ្ចឹមកូនមាន់ គ្មានមេៈ</u>

លក្ខណៈសាមញ្ញក្នុងការថែរក្សាកូនដែលទើបនឹងញាស់ ដែលកសិករភាគច្រើនអាចធ្វើបាន ជាពិសេសក្រោយពីមាន់ញាស់ ត្រូវទុកឲ្យវាស្ងួតរោម មុននឹងយកវាចេញពីសំបុក ហើយបន្ទាប់មក យើងត្រូវ ៖

- យកកូនមាន់ដាក់ចូលក្នុងឡាំង ឬ ល្អី ដែលយើងបានរៀបចំដូចជាសំបុកមាន់ ដែលធ្វើឲ្យកូនមាន់ កក់ក្តៅរឹងជើង ហើយបន្ទាប់មក ទើបយកវាដាក់ទ្រុងផ្តាច់កូន (បំបែកពីមេ)។
- ដាក់ទឹកស្អាត ឲ្យកូនមាន់ផឹកជាប់ជានិច្ច ។ ១២ ម៉ោងក្រោយមកត្រូវដាក់ចំណីកូនមាន់។ ចំណីដែលដាក់ឲ្យកូនមាន់ស៊ី ត្រូវសំបូរជីវជាតិប្រូតេអ៊ីន និងងាយរលាយ ដូចជា៖ ចំណីរោងចក្រ (ចំណីពីផ្សារ) ឬ សត្វល្អិតតូចៗ ជាដើម។
- នៅពេលយប់ ត្រូវចាប់កូនមាន់ដាក់ក្នុងឡាំង ឬ ល្អី ដែលយើងបានត្រៀមជាសំបុក និងគ្របកូនមាន់ឲ្យបានជិតល្អ (ខែក្តៅ គ្របក្រណាត់ស្តើងៗ និង ខែត្រជាក់ ត្រូវគ្របក្រណាត់ក្រាសបន្តិច) ដើម្បីឲ្យកូនមាន់ ទទួលបានភាពកក់ក្តៅ ជំនួសមេរបស់វា។

☞ *ត្រូវផ្តល់កំដៅឱ្យកូនមាន់ ដូចមេមាន់ផ្តល់ឱ្យកូនវាដែរ*

- បើសីតុណ្ហភាពទាប នោះ កូនមាន់នឹងខ្សោយ ងារ ឈឺ ហើយបណ្តាលឱ្យការលូតលាស់យឺត
- បើសីតុណ្ហភាពខ្ពស់នឹងធ្វើឱ្យរោមកូនមាន់ដុះមិនល្អ
- ត្រូវត្រៀមកំដៅសម្រាប់កូនមាន់
- ត្រូវផ្តល់ទឹក និងចំណីឱ្យបានគ្រប់គ្រាន់ និងមានគុណភាព

*តើយើងត្រូវបំបែកកូនមាន់ ចេញពីមេ នៅអាយុ ១០ថ្ងៃ បានយ៉ាងដូចម្តេច?*

❖ ការក្រុងរបស់មេៈ បើសិនមេមាន់ក្រុងកូនរបស់វាក្រោមស្លាបនោះ កូនមាន់ នឹងទទួលកំដៅ ៣៥-៣៧ អង្សារសេ។

- រៀបចំទ្រុងសម្រាប់ដាក់កូនមាន់រួចជាស្រេច ដោយបាតទ្រុងដាក់អង្កាម ឬ កំទេចអាចម៍រណារ
- ត្រូវយកទាំងមេ និងកូន ទៅដាក់ក្នុងទ្រុងកូនមាន់ជាមួយគ្នា ក្រោយពីកូនញាស់អស់
- ពេលកូនមាន់អាយុបាន ១០ថ្ងៃ ត្រូវដកមេចេញពីកូន ដោយយកទៅដាក់ក្នុងទ្រុងមេពង ។ មិនត្រូវឲ្យមេមាន់ចូលក្នុងទ្រុង ឬ មកក្បែរកូនមាន់ ឡើយ។ ត្រូវយកបាវ ឬ ក្រដាសព័ទ្ធជុំវិញទ្រុងកូនមាន់ ដើម្បីរក្សាកំដៅ។ បើសិនត្រជាក់ខ្លាំង ឬពេលយប់ ត្រូវបន្ថែមកំដៅ ដោយប្រើក្អមធ្យូងកំដៅ ឬ អំពូលភ្លើង (មូល) ១០០វ៉ាត់។
- កូនមាន់អាយុបាន ១ខែ ត្រូវយកទៅចិញ្ចឹមនៅក្នុងទ្រុងបំប៉នរហូតដល់ពេលលក់។



រូបទី២៤: ផ្តល់កំដៅកូនមាន់ ដោយប្រើរងើកធ្យូង



រូបទី២៥: ផ្តល់កំដៅកូនមាន់ដោយប្រើអំពូលភ្លើង

❖ សញ្ញាបង្ហាញពីកំដៅក្នុងទ្រុងកូនមាន់

- កំដៅល្មមគ្រប់គ្រាន់: កូនមាន់ដើររកស៊ីរាយប៉ាយល្អ ក្នុងទ្រុង
- កំដៅខ្លាំងជ្រុល: កូនមាន់ឃ្លាតឆ្ងាយពីប្រភពកំដៅ ឬ ស្រែកយំពេញទ្រុង ឬ រត់ប្រសេចប្រសាច
- កំដៅត្រជាក់ខ្លាំង: កូនមាន់ប្រមូលផ្តុំគ្នា ឬ គរលើគ្នា






រូបទី២៦: សញ្ញាបង្ហាញពីការទទួលកំដៅ របស់កូនមាន់

# ៨. ជីវសុវត្ថិភាព និងការធ្វើអនាម័យ

សុខភាពមាន់ គឺជាគន្លឹះដ៏សំខាន់សម្រាប់ការចិញ្ចឹម។ កសិករស្ទើរតែទាំងអស់មានការខាតបង់ ដោយសារការផ្ទុះឡើងនូវជម្ងឺផ្តាសាយបក្សី ឬ សំណាបមាន់ ស្ទើរគ្មានសល់ក្នុងមួយឆ្នាំៗ។

- ជម្ងឺបង្កឡើងដោយវីរុស គ្មានថ្នាំព្យាបាលទេ
- ជម្ងឺបណ្តាលមកពីបាក់តេរី អាចព្យាបាលបានខ្លះ ដោយប្រើថ្នាំ អង់ទីប៊ីយូទិច
- ជម្ងឺបណ្តាលមកពីបរាសិត (ព្រូន អង្កែ...) ព្យាបាលដោយថ្នាំទំលាក់ព្រូន ឬ សំលាប់អង្កែ។

មាន់អាចចម្លងជម្ងឺយ៉ាងរហ័សពីមួយទៅមួយ តាមរយៈកាកសំណល់ លាមក ទឹកសំបោរ ។ ជួនកាលអ្នកចិញ្ចឹមមិនអាចមើលដឹងថា មាន់ណាមួយមានផ្ទុកជម្ងឺឡើយ។

## ៨.១. អនាម័យកន្លែងចិញ្ចឹម

- សំអាតព្រៃជុំវិញកន្លែង (ទ្រុង)ចិញ្ចឹម
- លប់ដីគ្រលុកដក់ទឹកឲ្យបានស្អាតល្អ
- ត្រូវក្រាលបាតទ្រុងជាមួយអង្កាម ឬ កំទេចអាចម៍រណារ
- ក្នុងកន្លែងមាន់ដេក (ទ្រុង)ត្រូវបោស សំអាត កើបលាមកមាន់ចេញរាល់ថ្ងៃ
- ត្រូវសម្លាប់មេរោគ និង បរាសិត (ក្នុង ទ្រុង និងធ្លាចិញ្ចឹម) រៀងរាល់មុនពេលដាក់មាន់ យ៉ាងតិច ១ អាទិត្យ ដោយបាចកំបោរស ដើម្បីកុំឲ្យមាន់ឆ្លងមេរោគ។



រូបទី២៧: ការសម្លាប់មេរោគដោយបាចទឹកកំបោរខាងក្រៅ

## ៨.២. អនាម័យចំណីអាហារ និងទឹកផឹក

- មិនត្រូវយកទឹកកខ្វក់មកឲ្យមាន់ផឹកទេ។ ត្រូវផ្លាស់ប្តូរទឹកថ្មីមួយដងក្នុងមួយថ្ងៃ
- ចំណីដុះផ្សិត ផ្អូម មិនត្រូវផ្តល់ឲ្យមាន់ស៊ីទេ

## ៨.៣. ការរៀបចំការចិញ្ចឹម

- ត្រូវរៀបចំដាក់តាមប្រភេទ និងជំនាន់របស់វា (ក្រុមមេបា កូនជំទង់ កូនតូចៗ)
- មាន់ទិញ ឬ យកមាន់ចូលថ្មី ត្រូវរក្សាទុកវាដោយឡែកដាច់ពីគេ ចំនួន ១៤ថ្ងៃ ។ បន្ទាប់មក បើសិនវាមានសុខភាពល្អ ទើបដាក់ចូលជាមួយមាន់ចាស់បាន។



រូបទី ២៨: មុនបញ្ចូលមាន់ថ្មីត្រូវ រក្សាទុកយ៉ាងតិច ២ អាទិត្យ ដើម្បី តាមដានសុខភាពមាន់

## ៨.៤. អនាម័យការឆ្លងពីក្រៅ និងឧបករណ៍ចិញ្ចឹម

- មុនពេលចូលក្នុងទ្រុងមាន់ ត្រូវសម្លាប់មេរោគ ពិសេសដោយទឹកកំបោរជ្រលក់ស្បែកជើង ដែលដាក់នៅមាត់ច្រកចូល ជាមុនសិន ។
- ហាមមិនឲ្យមនុស្សពីក្រៅ (អ្នកដើរទិញមាន់ អ្នកចិញ្ចឹមកន្លែងផ្សេង) ចូលក្នុងកន្លែងចិញ្ចឹមមាន់
- ស្នូកទឹក ស្នូកចំណីត្រូវឧស្សាហ៍លាងសំអាតជារៀងរាល់ថ្ងៃ ពេលផ្លាស់ប្តូចំណីឬ ទឹកឲ្យមាន់ស៊ីផឹក
- ប្រសិនបើមាន់ងាប់ ត្រូវកប់ ឬ ដុតចោល ។ មិនត្រូវបោះវាចោល ពាសវាលពាសកាល នោះទេ ។
- មិនត្រូវបរិភោគមាន់ដែលងាប់ដោយសារជម្ងឺ ទេ ។



រូបទី ២៩: ការកប់ ឬ ដុតបំផ្លាញចោលមាន់ ដែលងាប់ដោយសារជម្ងឺ




រូបទី៣០: ដាក់ទឹកកំបោរថ្ម នៅមាត់ច្រកចូល ដើម្បីសំអាតបាតស្បែកជើងមុនពេលចូលក្នុងទ្រុងមាន់

# ៩. ជម្ងឺសំខាន់ៗ របស់មាន់ ការការពារ និង ព្យាបាល

ឲ្យ❋ឲ

មានជម្ងឺជាច្រើនប្រភេទដែលតែងតែបង្កការលំបាកដល់ការចិញ្ចឹមមាន់របស់កសិករនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឯកសារចនេះយើងសូមលើកយកតែជម្ងឺសំខាន់ៗមួយចំនួនដែលតែងតែកើតមានឡើងញឹកញាប់មកបង្ហាញតែប៉ុណ្ណោះ។

## ៩.១. ជម្ងឺមាន់ដែលបង្កដោយពពួកបរាសិត

### ៩.១.១. បរាសិតខាងក្រៅ

មាន់ តែងតែទទួលរងការរាតត្បាតនៃពពួកបរាសិតខាងក្រៅ កាលណាកន្លែងចិញ្ចឹមមិនស្អាត។

**<u>ក- រោគសញ្ញា</u>**

មាន់បង្ហាញសញ្ញាដូចជាមិនសូវបានដេក មិនសូវស៊ីចំណី នៅមិនស្ងៀម មានរបួដោយសារការអេះ ឬ ចឹក ដោយសារមានភាពរមាស់ ចំនួនស៊ុតថយចុះ ចុះស្គម មានសភាពស្លេកស្លាំង ដោយសារខ្វះឈាម។ ពពួកបរាសិតខាងក្រៅ មានៈ ចៃ ស្រមើល មេកមររមាស និង ដង្កែ ។



រូបទី ៣១: ចៃមាន់



រូបទី ៣២: ចៃមាន់ និងស្នាមរបួសស្បែក

**ខ- វិធានការណ៍ព្យាបាល និងការពារ**

- ប្រើប្រាស់ថ្នាំខ្លាំង ឬ ថ្នាំបាញ់មូសទៅលើកន្លែង ដែលមានសង្ស័យថាមានបរាសិតខាងក្រៅ។
- ប្រើថ្នាំ អ៊ីយ៉ូឌីន និង អង់ទីប៊ីយ៉ូទិច ដើម្បីព្យាបាលរបួសរបស់មាន់
- អនាម័យកន្លែងមាន់ឲ្យបានស្អាត
- ប្រើថ្នាំខ្លាំង ឬ គល់ស្លឹកគ្រៃ ដាក់ក្នុងសំបុកមេមាន់ក្រាបពង
- កំចាត់សត្វល្អិតៈ ត្រូវសម្អាតកន្លែងមានីដេករាល់ថ្ងៃ និងរៀបកន្លែងសម្រាប់បំពង ដីលេងដោយប្រើផេះ ២០ ភាគ និងខ្សាច់ ៦ភាគ។

## ៩.១.២. បរាសិតខាងក្នុង

បរាសិតខាងក្នុង ធ្វើឲ្យប៉ះពាល់ដល់ការធំធាត់របស់មាន់ ហើយជាទូទៅ កសិករ មិនដែលបានគិតដល់សោះ។ ពពួកបរាសិតខាងក្នុងរួមមានៈ ព្រូនចង្កិះ ព្រូនមូល តេនញ៉ា......។ល។

**ក- រោគសញ្ញា**

មាន់មានសភាពស្គម រាគ មានវត្ថុមានព្រូននៅក្នុងលាមក ក្នុងភ្នែក ការលូតលាស់យឺត និង ងាយកើតជម្ងឺផ្សេងៗ ។





| រូបទី៣២.កៈ ព្រូនមូលនៅក្នុងពោះវៀនមាន់ | រូបទី៣២.ខៈ ព្រូនសំប៉ែតនៅក្នុងពោះវៀនមាន់ |
|---|---|

**ខ - វិធានការណ៍ព្យាបាល និងការពារ**

- ប្រើថ្នាំទម្លាក់ព្រូនប្រភេទ ឡឺវ៉ាមីសុល(Levamizole) ១កញ្ចប់ (២ ក្រាម ) សម្រាប់ទម្ងន់មាន់ ៥ គីឡូក្រាម លាយជាមួយចំណីឲ្យមាន់ស៊ី។
- ទម្លាក់ព្រូន នៅពេលមាន់មានអាយុ ១ខែ និងធ្វើម្តងទៀត ពេលមាន់មានអាយុ ពី២ ទៅ ៣ខែ។
- អនុវត្តអនាម័យឲ្យបានខ្ជាប់ខ្ជួន។



រូបទី៣៣ៈ ព្រូនមូលនៅក្នុងលាមកមាន់

## ៩.២. ជម្ងឺមាន់ដែលបង្កដោយពពួកបាក់តេរី និង វីរុស

ជម្ងឺមាន់ ជាជម្ងឺកាចសាហាវ មានការរាលដាលខ្លាំង និង បណ្តាលឱ្យមាន់ងាប់ច្រើន។ ហើយជម្ងឺភាគច្រើន ជាជម្ងឺ មិនអាចព្យាបាលបាន ដូច្នេះ វិធីដែលប្រសើរបំផុត គឺ ការចាក់ថ្នាំបង្ការការពារ (វ៉ាក់សាំង) ជាមុន ។

### ៩.២.១. ជម្ងឺញូវកាស

ជម្ងឺ ញូវកាស (ជួនកាល កសិករ ហៅតាមតំបន់ថា ពពកវិល ដង្កោរែក..) ជាជម្ងឺមួយដែលបង្កដោយវីរុស ហើយតែងតែកើតមានឡើងនៅរដូវក្តៅ។ ជម្ងឺបង្កឲ្យមានការខាតបង់យ៉ាងច្រើនដល់កសិករចិញ្ចឹមមាន់ ជាពិសេស ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ។ មាន់ ត្រូវបានងាប់ស្ទើតែទាំងស្រុង នៅពេលដែលមានជម្ងឺនេះ ជាពិសេស មាន់តូចៗ។

**ក - ការចម្លងជម្ងឺ**

ជម្ងឺនេះ អាចឆ្លងតាមរយៈ

- ខ្យល់ ចំណី និងទឹក ដែលមានមេរោគ
- ការប៉ះពាល់រវាងមាន់ឈឺ និង មាន់ជា
- សត្វល្អិត សត្វកណ្តុរ សម្ភារៈ និង សម្លៀកបំពាក់... ។ល។
- សត្វងាប់ ហើយមិនបានដុត ឬ កប់ចោលឲ្យបានត្រឹមត្រូវ
- ចរាចរបក្សី ផលិតផលសត្វ មនុស្ស និងឧបករណ៍ ពីតំបន់ដែលមានជម្ងឺ
- ការចាក់ការពារវ៉ាក់សាំងការពារ មិនបានត្រឹមត្រូវ

**ខ- រោគសញ្ញា**

ចំពោះកូនមាន់វាបានបង្ហាញរោគសញ្ញាដូចជា សំកុក ថយកម្លាំង ។ គេសង្កេតឃើញកូនមាន់មកនៅផ្តុំគ្នា នៅមួយជ្រុងនៃទ្រុង ហើយដេកគរលើគ្នា។ វាមានសភាពញ័រញាក់ ដើរខ្ញើចជើង រាគពណ៌ស កណ្តាស់ ក្អក និង ដកដង្ហើមឮសូរ។ កូនមាន់អាចបញ្ចេញសញ្ញាសរសៃប្រសាទ ក្រោយពេលឈឺបាន២ ទៅ ៣ថ្ងៃ ដូចជា ទម្លាក់ស្លាប ដើរអូសជើង រមួលក្បាល និងក និង ដើរវិលវល់។

ចំពោះមាន់ធំ មានរោគសញ្ញា ដូចជា មាន់ធំ ១-២ ក្បាលងាប់ភ្លាមៗ ហើយឯមាន់ដទៃទៀត បន្តឈឺ ដោយ បង្ហាញរោគសញ្ញាដូចជា សំកុក ខ្សោយ រោមបះ ដកដង្ហើមឮសូរសម្លេងស្អកៗ រាគទឹក បន្ទាប់មកក្លាយជាព៌ណខៀវ ហើយពងមានចំនួនថយចុះ។ មាន់ដែលមិនទាន់ងាប់ អាចបង្ហាញនូវសញ្ញាសរសៃប្រសាទ ដូចជា រមួលកមកក្រោយ និង ដើរវិលវល់។ កាជៀតចូលនៃបាក់តេរីឱកាសនិយមផ្សេងទៀត ធ្វើឲ្យមាន់មានបញ្ហាផ្លូវដង្ហើមកាន់តែធ្ងន់ធ្ងរ។



រូបទី៣៤: មាន់សំកុក មិនស៊ីចំណី និង រមួលក និងក្បាលទៅក្រោយ

**គ - វិធានការណ៍ព្យាបាល និង ការពារ**

ជម្ងឺនេះ គ្មានថ្នាំសម្រាប់ព្យាបាលទេ តែអាចបង្ការការពារជម្ងឺ បានដោយ៖

- ចាក់វ៉ាក់សាំងការពារឲ្យបាន ២ដងក្នុង១ឆ្នាំ (ធ្វើវ៉ាក់សាំងលើកូនមាន់អាយុ ១ ថ្ងៃ និង ៣សប្តាហ៍ ក្រោយទើបអាចការពារបាន ៦ខែ។
- បំបែកសត្វឈឺ ពីសត្វជា កប់ ឬ ដុតសាកសពសត្វដែលងាប់
- បាញ់ថ្នាំសម្លាប់មេរោគ និងអនុវត្តអនាម័យកន្លែងមាន់ឈឺ និង បរិវេណជុំវិញទ្រុង
- ក្រុងមាន់ដែលទើបទិញចូលថ្មី ឲ្យបានយ៉ាងហោចណាស់ ១៤ ថ្ងៃ ដោយសារតែជម្ងឺនេះវាឆ្លងចូលទៅក្នុងខ្លួនសត្វជាមធ្យម ២សប្តាហ៍ ទើបមានការលេចឡើងនូវរោគសញ្ញា (ឲ្យដឹងថាឈឺ)។

### ៩.២.២. ជម្ងឺអុត

ជម្ងឺអុត ជាជម្ងឺដែលបង្កឡើងដោយវីរុស។ ជម្ងឺនេះតែងតែកើតឡើងរដូវក្តៅ ហើយមិនសូវមានអត្រាងាប់ខ្ពស់ទេ បើសិនមានការថែទាំមាន់ ដែលឈឺបានល្អ ។ អត្រាស្លាប់ អាចមានកម្រិតខ្ពស់ ចំពោះកូនមាន់។

**ក - ការចម្លងជម្ងឺ**

ជម្ងឺនេះ អាចឆ្លងតាមរយៈ ៖

- តាមការឆ្លងដោយផ្ទាល់ពីបក្សីឈឺទៅបក្សីជា
- តាមការទិច ឬ ខាំរបស់សត្វល្អិតផ្សេងៗ ដូចជាមូសជាដើម
- តាមរបួសដែលកើតមានដោយសារចឹកគ្នា និងការប៉ះពាល់ជាមួយស្បែកដែលដាច់ និងមូលហេតុផ្សេងៗ

**ខ- រោគសញ្ញា**

- មានដុំពក ឬ ដំបៅពណ៌ក្រហមក្រម៉ៅលើស្បែក ពិសេស ម្តុំក្បាល ក្បាល ច្រមុះ និងកន្លែងដែលមិនរោមដទៃទៀត។ បើកើតលើភ្នែក អាចបណ្តាលឲ្យមាន់ខ្វាក់បាន។



រូបទី៣៥: រោគសញ្ញាជម្ងឺអុតនៅលើមុខមាន់

**គ- វិធានការណ៍ព្យាបាល និងការពារ**

- គ្មានថ្នាំព្យាបាលមានប្រសិទ្ធភាពទេ ប៉ុន្តែយើងអាចប្រើប្រាស់ថ្នាំ អង់ទីប៊ីយ៉ូទិច និងអ៊ីយ៉ូឌីន លាបលើស្នាមពងបែកនោះ។ (សូមចាំថា កូនមាន់ដែលព្យាលបាលជា នឹងក្រិន លូតលាស់មិនសូវលឿន)។
- ជម្ងឺនេះ អាចការពារបានដោយការចាក់វ៉ាក់សាំងការពារជម្ងឺអុត លើកូនមាន់ដែលមានសុខភាពល្អ នៅពេលវាមានអាយុពី ៧ ទៅ ១៤ថ្ងៃ។
- បំបែកសត្វឈឺចេញពីសត្វជា
- កប់ ឬ ដុតសាកសពកូនមាន់ ដែលងាប់
- ការពារកូនមាន់ ពីការខាំរបស់សត្វល្អិតផ្សេង

## ៩.២.៣. ជម្ងឺអាសន្នរោគ

ជម្ងឺអាសន្នរោគ គឺជាជម្ងឺមួយ ដែលង្កឡើងដោយបាក់តេរី ដែលបណ្ដាលឲ្យមានមាន់ឈឺ និងងាប់យ៉ាងច្រើន ហើយវាច្រើនកើតមាននៅរដូវសើម។ ជម្ងឺនេះច្រើនកើតឡើង ដោយជាប់ទាក់ទងជាមួយពពួក មីកូប្លាស្មា បរាសិតកង្វះវីតាមីន និងខ្វះអនាម័យ។

**ក- ការចម្លងជម្ងឺ**

ជម្ងឺនេះ អាចឆ្លងតាមរយៈ៖

- ការដាក់មាន់ថ្មី ដែលមានជម្ងឺ
- ការប៉ះពាល់រវាងបក្សីមានជម្ងឺ ជាមួយនិងបក្សីជា ឬ បក្សីដែលទើបជាពីជម្ងឺ
- កាកសំណល់ ឬ សម្ភារៈ ដែលមានផ្ទុកមេរោគ
- តាមរយៈសត្វល្អិត កណ្ដុរ ល....។ល

**ខ- រោគសញ្ញា**

ខ-១. ទម្រង់ស្រួចស្រាវ ៖

- ងាប់ភ្លាមៗ ( ធ្លាក់ពីលើទ្រនំ )ឬ កំពុងរកស៊ីចំណី ស្រាប់តែប្រកាច់ងាប់មួយរំពេច ដោយមិនមានរោគសញ្ញាអ្វីទាំងអស់ ហើយមាន់ដែលងាប់ភាគច្រើនជាមាន់ដែលធំ និងធាត់ទៀតផង ។



រូបទី៣៦: លាមកមាន់រាគ និង មានពណ៌បៃតង

ខ-២. ទម្រង់រាំរៃ ៖

- ពិបាកដកដង្ហើម ដង្ហក់ ហើមសិរណង់ ជើង និងបាតជើង មានហូរទឹករំអិលពីច្រមុះ មានខ្ទុះក្នុងភ្នែក និងចំពុះ ហើយមានលាមករាគពណ៌លឿងបៃតង។

គ- វិធានការណ៍ព្យាបាល និងការពារ

- ប្រើថ្នាំ តេរ៉ាមីស៊ីន ៥០០ក្រាម (អុកស៊ីតេត្រាស៊ីគ្លីន) ច្រកតាមមាន់ ឬ ប្រើថ្នាំ អុកស៊ីតេត្រាស៊ីគ្លីន ចាក់កម្រិត ៥០មីលីក្រាម សម្រាប់មាន់ ១ក្បាល(0,៥0សេសេ នៃថ្នាំ អុកស៊ីតេត្រាស៊ីគ្លីន ១0%) ដើម្បីព្យាបាលជម្ងឺនេះ
- គេអាចការពារបានដែរ ដោយប្រើវ៉ាក់សាំងការពារជម្ងឺ អាសន្នរោគ
- អនុវត្តនូវអនាម័យឲ្យបានខ្ជាប់ខ្ជួន ដើម្បីការពារការឆ្លងជម្ងឺនេះ
- ជៀសវាងកុំឲ្យមេរោគចូលទៅក្នុងដី ចាំបាច់ត្រូវដុតសាកសពមាន់ចោល នៅពេលមាន់ងាប់។

៩.២.៤. ជម្ងឺផ្តាសាយបក្សី

ផ្តាសាយបក្សី គឺជាជម្ងឺថ្មី ដែលទើបនឹងកើតមានក្នុងប្រទេសកម្ពុជានៅកំឡុងឆ្នាំ ២00៤ ។ ជាជម្ងឺបង្កឡើងដោយ វីរុស ដែលមិនត្រឹមតែបក្សីស្រុក និង បក្សីព្រៃប៉ុណ្ណោះទេ ថែមទាំអាចចម្លង និងសម្លាប់មនុស្សបានទៀតផង ។

**ក - ការចម្លងជម្ងឺ**

ជម្ងឺនេះអាចឆ្លងតាមរយៈ ៖

- ការប៉ះពាល់ផ្ទាល់រវាងបក្សីឈឺ និង បក្សីជា
- ឆ្លងតាមការដកដង្ហើម ទឹកសំបោរ លាមក រោម ស្លាប និង ទឹករំអិល
- សម្ភារៈផ្សេងៗដែលមានផ្ទុះមេរោគ និង មធ្យោបាយធ្វើដំណើរ
- ការប៉ះពាល់ដោយផ្ទាល់ ឬ ប្រយោលរវាងបក្សីស្រុក (មាន់ ទា...) ជាមួយបក្សីព្រៃដែលមានជម្ងឺនេះ ឬ សាកសព ឬ កាកសំណល់ (លាមក ទឹករំអិល វត្ថុរាវ...) របស់បក្សីព្រៃដែលមានជម្ងឺ...។ល។

## ខ- រោគសញ្ញា

វាបានបង្ហាញរោគសញ្ញា ដូចជា៖

- សត្វងាប់ច្រើន
- ដំណើរទន់  សំយ៉ុងក្បាល ហើមមុខ និងហៀរសំបោរ
- មានស្នាមជាំឈាម នៅលើជើង ក្បាល ខ្វិន ....។ល។

## គ - វិធានការណ៍ព្យាបាល និងការពារ

ចំពោះជម្ងឺនេះ មិនអាចព្យាបាលបានទេ ។ ដើម្បីការពារជម្ងឺនេះ យើងត្រូវ៖

- ដុត ឬ កប់សាកសពមាន់ ដែលស្លាប់ដោយសារជម្ងឺនេះ
- មិនត្រូវលក់ ឬទិញមាន់ដែលឈឺ ឬ ងាប់ទៅកន្លែងផ្សេងឡើយ
- ធ្វើចត្តាឡីស័កនៅកន្លែងផ្ទុះជម្ងឺ
- ផ្តល់ព័ត៌មានដល់ភ្នាក់ងារពេទ្យសត្វភូមិ ពេទ្យសត្វស្រុក ពេទ្យសត្វខេត្ត ឬ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល។

# ១០. លក្ខណៈទូទៅរបស់ថ្នាំបង្ការ (វ៉ាក់សាំង)

លក្ខណៈទូទៅរបស់ថ្នាំបង្ការ (ឬ វ៉ាក់សាំង) គឺ

- វ៉ាក់សាំងជាថ្នាំសម្រាប់បង្ការការពារជម្ងឺ មិនមែនជាថ្នាំសម្រាប់ព្យាបាលទេ
- សត្វដែលអាចចាក់វ៉ាក់សាំងបាន គឺ នៅពេលដែលវាមានសុខភាពល្អ
- វ៉ាក់សាំង ១មុខ អាចការពារជម្ងឺបានតែ ១មុខ ប៉ុណ្ណោះ
- ថ្នាំការពារខុសគ្នា មានវិធីប្រើខុសគ្នា (ផ្លូវបញ្ចូលថ្នាំ)
- ថ្នាំការពារជម្ងឺដូចគ្នា តែផលិតដោយក្រុមហ៊ុនខុសគ្នា ក៏អាចមានវិធីប្រើប្រាស់ខុសគ្នាដែរ ។ ដូច្នេះគប្បីត្រូវដឹងឱ្យបានច្បាស់ពីវិធីប្រើប្រាស់ និង កំរិតប្រើប្រាស់វ៉ាក់សាំងនិមួយៗ ។
- វ៉ាក់សាំងដែលនៅសល់ពីការប្រើប្រាស់ត្រូវដុតចោល
- អ្នកត្រូវកត់ត្រា ថ្ងៃ ខែ និង ចំនួនមាន់ចាក់វ៉ាក់សាំង
- ត្រូវចាក់ថ្នាំការពារដល់មាន់ទាំងអស់ និង ចាក់បានទៀងទាត់ ទើបមានប្រសិទ្ធិភាព។

✌ **<u>តារាងកម្មវិធីចាក់ថ្នាំការពារជម្ងឺមាន់</u>**

| អាយុ | ឈ្មោះវ៉ាក់សាំងការពារជម្ងឺ | ផ្លូវបញ្ចូល | រំលឹកឡើងវិញក្រោយចាក់ |
|---|---|---|---|
| ពី៣ ទៅ ៥ ថ្ងៃ | ជម្ងឺដង្កោកាច់ (ញ៉ូកាស I 2) | បន្តក់ក្នុងភ្នែក/ច្រមុះ | ៦ ខែ |
| ពី៧ ទៅ ១០ ថ្ងៃ | ជម្ងឺអុតមាន់ | ជួសស្បែកផ្ទាំងស្លាបរង | ១ ឆ្នាំ |
| ២ ខែ | ជម្ងឺអាសន្នរោគ | ចាក់សាច់ដុំ | ៦ ខែ |

<u>បញ្ជាក់:</u> ក្នុងករណីមាន់ទុកសម្រាប់ធ្វើមេ និងបា ត្រូវចាក់រំលឹកឡើងវិញ រៀងរាល់ ៥-៦ខែ ម្តង (ជម្ងឺញូវកាស ជម្ងឺអាសន្នរោគ និង ជម្ងឺរលាកផ្លូវដង្ហើម)



<u>រូបទី៣៧</u>: ការបន្តក់ភ្នែក-ច្រមុះ (ជម្ងឺញូកាស)



<u>រូបទី៣៨</u>: ជួសស្លាបរងកូនមាន់ (ជម្ងឺអុតបក្សី)



រូបទី៣៩: ការចាក់សាច់ដុំ (ជម្ងឺ អាសន្នរោគ)

# ១១. ការកត់ត្រាចំណាយ ចំណូលផលិតកម្ម

## ១១.១. ការកត់ត្រាចំណាយ ចំណូលផលិតកម្ម

ការកត់ត្រាទុកនូវតួរលេខចំណាយចំណូល មានសារៈសំខាន់ណាស់ ។ មាន ហេតុផលជាច្រើន ដែលគេចាំបាច់ត្រូវកត់ត្រាជាប្រចាំ ពីចំណាយ ចំណូល ផលិតកម្ម ។ ហេតុផលចំបងមួយចំនួន មានដូចជា៖

- ប្រសិនបើគ្មានការកត់ត្រាពីអ្វីដែលត្រូវបានចំណាយ ហើយអ្វីដែលបានចំណូលនោះទេ យើងនឹងមិនអាចដឹងបានទេ ថាតើ មុខជំនួញរបស់យើង ខាត ឬ ចំណេញ? ចូរចងចាំថា ការទទួលបានប្រាក់ចំណូលរាល់ថ្ងៃ មិនមានន័យថា យើងបានទទួលប្រាក់ចំណេញនោះទេ ។
- ប្រសិនបើយើងដឹងច្បាស់ពីមុខចំណាយ និង មុខចំណូលច្បាស់លាស់ យើងអាចរិះរកវិធីដើម្បី គ្រប់គ្រងជំនួញ ឲ្យបានកាន់តែល្អ កាន់តែបានចំណេញច្រើន។
- កំណត់ត្រាអាចត្រូវប្រើប្រាស់សម្រាប់ធ្វើផែនការចំណាយនៅពេលអនាគត ព្រោះយើងអាចដឹងពីតំលៃ និង ធនធានដែលត្រូវចំណាយ ។

គោលដៅចំបងនៃធ្វើជំនួញ ឬ ផលិតកម្មអ្វីមួយ គឺរកបានចំណេញ និង កាន់តែចំណេញច្រើន ។ ប្រាក់ចំណេញ ជាផលសង (ឬ ភាពខុសគ្នាជាវិជ្ជមាន) រវាង ទឹកប្រាក់ចំណូល (បានមកពីលក់ផលិតផល ឬ សេវាកម្ម) និង ទឹកប្រាក់ចំណាយទាំងអស់ ។ ចំណាយ អាចបែងចែកជា ២ ប្រភេទ គឺ ៖

(១) **ចំណាយថេរ** (មិនប្រែប្រួល [1]) គឺជា ចំណាយមូលធន ដូចជា ដី សំណង់ ឃ្លាំង រោងបណ្តុះផ្សិត ទ្រុងមាន់ គ្រឿងចក្រ...... ដែលមានតំលៃ (ត្រូវកាត់ រំលស់) ជាប្រចាំ ទោះជាមានការផលិត ឬក៏ គ្មានក៏ដោយ ។ ដោយសារឧបករណ៍ និង សម្ភារៈ ក្នុងមុខចំណាយថេរ ទាំងនេះ អាចប្រើបានច្រើនដង (ប្រើម្តងមិនអស់) ហើយ អាចប្រើនៅក្នុងផលិតកម្ម សារក្រោយៗទៀតនោះ គេត្រូវគិតរំលស់វា ជាច្រើនសារ។ ការកំណត់ចំនួនសាររំលស់ ថ្លៃឧបករណ៍ និង សម្ភារៈ ក្នុងប្រភេទចំណាយថេរនេះ អាចគិតបានច្រើនបែប ដូចជា តាម ចំនួនសារ (ដង) ផលិតកម្ម តាមអាយុកាល (រយៈពេល) អាចនៅប្រើបានរបស់វា ...... ។

(២) **ចំណាយប្រែប្រួល** គឺជាប្រភេទចំណាយជាក់ស្តែងសម្រាប់ការផលិត ផលិតផល ឬ សេវាអ្វីមួយ ។ ការចំណាយប្រភេទនេះ រួមមាន វត្ថុធាតុដើម ដូចជា គ្រាប់ពូជ ដី ថ្នាំ កំបោរស ការរៀបចំដី ពលកម្ម ...... ដែលត្រូវការ ចាំបាច់សម្រាប់ផលិតរបស់ ឬ ផលិតផលអ្វីមួយ (ដូចជា ផ្សិតចំបើង មាន់ ជ្រូក......) ។

---

[1] នៅពេលទិញ ឬ សាងសងហើយ (គឺថា បានចំណាយហើយ) ទោះបីប្រើ ឬ មិនប្រើក្តី សម្រាប់ការផលិតទំនិញ(ផលិតផល) អ្វីមួយ ក៏ដោយ ក៏គុណភាព (គឺវាក្លាយបន្តិចម្តងៗ ទៅជារបស់ចាស់ សឹករេចរិល...... ) ហើយ តំលៃរបស់វា នឹងត្រូវបាត់បង់បន្តិចម្តងៗ ទៅតាមនោះដែរ។

ដើម្បីឲ្យដឹងច្បាស់ ថាតើគោលដៅជោគជ័យជំនួញ សម្រេចបានត្រឹមណានោះ គេត្រូវការនូវព័ត៌មានជាចាំបាច់ ដែលមិនអាចរកបាន ក្រៅពីការកត់ត្រាជាប្រចាំ និង បានត្រឹមត្រូវរបស់យើង នោះឡើយ ។ ការកត់ត្រាអាចផ្តោតលើការប្រមូលព័ត៌មានចាំបាច់ សម្រាប់វិភាគចំណាយ និង ចំណេញ និង តម្រង់ទិសមុខរបរ ឬ ផលិតកម្មតាមពេលវេលា ឲ្យចំ ឆ្លើយតបតម្រូវការទីផ្សារ និង ទៅអនាគតខាងមុខ ។ ខាងក្រោមនេះ ជាទម្រង់កត់ត្រា [2] សាមញ្ញមួយ ដែលកសិករ (ចិញ្ចឹមមាន់) អាចប្រើសម្រាប់កត់ត្រាចំណាយ ចំណូលរបស់ខ្លួន ។

ក. <u>តារាងចំណាយ</u>

ឈ្មោះផលិតកម្ម:.........................................

ថ្ងៃចាប់ផ្តើមផលិតកម្ម:...................................... ថ្ងៃបញ្ចប់ផលិតកម្ម:..........................

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ខ. <u>តារាងចំណូល</u>

ឈ្មោះផលិតកម្ម:.........................................

ថ្ងៃចាប់ផ្តើមផលិតកម្ម:...................................... ថ្ងៃបញ្ចប់ផលិតកម្ម:..........................

| ល.រ | មុខចំណូល | ឯកតា | ចំនួន | តំលៃ ១ឯកតា | ទឹកប្រាក់សរុប |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

[2] តាមគំរូ <u>សៀវភៅកត់ត្រាគ្រប់គ្រងកសិដ្ឋានកសិករ</u> របស់គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ ទន្លេសាប។

## ១១.២. ការប្រើប្រាស់ព័ត៌មានប្រមូលបាន សម្រាប់វិភាគចំណាយចំណូលផលិតកម្ម

ដើម្បីទទួលបានព័ត៌មាន ចាំបាច់ ត្រឹមត្រូវ គេត្រូវកំណត់ឲ្យបានច្បាស់ពីមុខចំណាយ និង ចំណូលទាំងអស់ ហើយកត់ត្រាបានជាប្រចាំ និង បានត្រឹមត្រូវពីព័ត៌មាន ដែលបានកំណត់ទាំងនោះ ។ ព័ត៌មានប្រមូលបានទាំងនេះ នឹងត្រូវប្រើសម្រាប់វិភាគសេដ្ឋកិច្ច (គឺ ថ្លៃដើមផលិតផល និង ប្រាក់ចំណេញ) របស់ផលិតកម្មណាមួយ ។ ខាងក្រោមនេះ គឺជា គំរូកត់ត្រា និង វិភាគចំណាយ និង ចំណូលនៃការចិញ្ចឹមបំប៉នមាន់ស្រុក របស់កសិករម្នាក់ នៅស្រុក ជើងព្រៃ ខេត្តកំពង់ចាម។



<u>កសិករ/អ្នកចិញ្ចឹម៖</u> លោក ជ័យ រ៉ា នៅភូមិ សែនសុនជើង ឃុំ ស្រងែ ស្រុក ព្រៃឈរ ខេត្ត កំពង់ចាម (ទិញកូនមាន់ 100 ក្បាល ពីកសិដ្ឋានភ្ញាស់កូនមាន់ របស់គម្រោងTSTD នៅ ភូមិ ភ្នៅកើត ឃុំ ព្រៃចារ ស្រុកជើងព្រៃ ខេត្ត កំពង់ចាម)។

<u>ពេលវេលាប្រមូលផល៖</u> ខែ មិនា ឆ្នាំ 2013 (ចិញ្ចឹមបំប៉នរយៈពេល 3ខែ បន្ទាប់ពីដាក់កូន អាយុ 21ថ្ងៃ)

| ល.រ | បរិយាយ | ឯកត្តា | ចំនួនឯកត្តា | ថ្លៃ1 ឯកត្តា | សរុប (ដុល្លា) |
|---|---|---|---|---|---|
| 1. | ចំណាយសរុប | | | | 413 |
| 1.1 | កូនមាន់(អាយុ 3 អាទិត្យ) | ក្បាល | 100 | 1 | 100 |
| 1.2 | ចំណីផ្សំស្រេច/បាវ (30គីឡូ) | បាវ | 4 | 19,5 | 78 |
| 1.3 | កន្ទក់ម៉ដ្ត | គីឡូ | 200 | 0,21 | 42,5 |
| 1.4 | ចុងអង្ករ | គីឡូ | 150 | 0,28 | 41,25 |
| 1.5 | បន្លែ | គីឡូ | 250 | 0,13 | 31,25 |
| 1.6 | កូនត្រី និង ចំណាយរៀបចំ/ចំអិន | គីឡូ | 60 | 0,25 | 15 |
| 1.7 | ថ្នាំទម្លាក់ព្រូន វ៉ាក់សាំង វីតាមីន | សរុប/វគ្គ | 1 | 14,80 | 14,80 |
| 1.8 | ទ្រុង និង សម្ភារៈចិញ្ចឹម (សរុប រំលស់ ក្នុង 1វគ្គ) | សរុប/វគ្គ | 1 | 5,56 | 5,56 |
| 1.9 | ពលកម្ម (ថែទាំ ផ្តល់ចំណី 2ម៉ោង ក្នុង 1ថ្ងៃ) | សរុប/វគ្គ | 180 | 0,47 | 84,38 |
| 1.10 | ផ្សេងៗ (ដឹកជញ្ជូនកូនមាន់....) | សរុប/វគ្គ | 1 | 0,63 | 0,63 |
| 2. | <u>ចំណូលសរុប</u> | | | | 540 |
| | មាន់រស់បានលក់ (96ក្បាល 1ក្បាលទម្ងន់មធ្យម 1,3គីឡូ) | គីឡូ | 120 | 4,50 | 540 |
| 3. | <u>ចំណេញសុទ្ធ</u> | | | | |
| | ចំណេញសុទ្ធ ក្នុង 1 វគ្គចិញ្ចឹម (100 ក្បាល រយៈពេល 3ខែ បន្ទាប់ពីដាក់កូនចិញ្ចឹមបំប៉ន) | | | | 170 ដុល្លា<br>506.500 រៀល |

# ឯកសារយោង


១. សៀវភៅណែនាំបច្ចេកទេសស្តីពី *ការចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ* របស់គម្រោង TSTD (2013)

២. សៀវភៅណែនាំបច្ចេកទេសស្តីពី *ការភ្ញាស់កូនមាន់ស្រុកសម្រាប់លក់* របស់គម្រោង TSTD (2013)

៣. សៀវភៅណែនាំបច្ចេកទេសស្តីពី *ការចិញ្ចឹមមាន់ស្រុកជាលក្ខណៈគ្រួសារ* របស់គម្រោង PGM2 (2013)

